អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D345/1/6

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៩)

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 08 / 2017
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សាធារណៈ: កោសល្យុប

## សេចក្តីពិចារណាលើសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាចាត់ចូលនីតិវិធីស្តីពីសំណើ

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់សំណើ:**

សូ មុស្សេរឌ្ឌី
Susana TOMANOVIC
Neville SORAB

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលយក "សំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កូត" ដែលមេធាវីការពារក្តី [redacted] ("មេធាវីការពារក្តី" និង "ម្ចាស់សំណើ") បានដាក់នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ("សំណើសុំ")[1]។

## I. សេចក្តីផ្តើម

1. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានបញ្ជូនសំណើសុំមកអង្គបុរេជំនុំជម្រះនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៧[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ដោយចោទប្រកាន់ពីការចូលរួមរបស់ម្ចាស់សំណើនៅក្នុងអំពើល្មើស និងស្នើសុំឲ្យចោទប្រកាន់មកលើរូបគាត់[3]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ និងថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួនបី[4]។ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ[5] ហើយក្រោយមក ស.ព.អ បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី៥[6]។

---

[1] សំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កូត ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D345/1/2 ("សំណើសុំ")។

[2] ដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំមោឃភាពកិច្ចស៊ើបសួរ និងដីកាសម្រេចលើទំនប់កង្កូត ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D345/1 ("ដីកាសម្រេចលើពាក្យសុំ")។

[3] សំណុំរឿង ០០៤/០៧-០៩-២០០៩ អ.វ.ត.ក/ក.ស.ច.ស (សំណុំរឿង០០៤) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣")។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[4] សំណុំរឿង០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D65 ("ដីកាសន្និដ្ឋានបញ្ជូនរឿង



PRE-TRIAL CHAMBER E.C.C.C.

3. នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ [redacted] បានបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អ ដែលបានជូនដំណឹងគាត់ពីបទចោទនានាមកលើរូបគាត់ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ក្នុងចំណោមទីកន្លែងផ្សេងទៀត នៅ ទំនប់កង្គត និងបានអនុញ្ញាតឱ្យមេធាវីការពារក្តីរបស់គាត់ចូលពិនិត្យមើលសំណុំរឿង[7]។

4. នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦ បន្ទាប់ពីមានសំណើរបស់ ស.ច.ស.អ[8] ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដែលមានការកែតម្រូវ[9]។

5. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ មេធាវីការពារក្តីបានដាក់សំណើមួយនៅចំពោះមុខ ក.ស.ច.ស ស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាបង្គាប់ពាក់ព័ន្ធ

---

ឱ្យស៊ើបសួរបន្ថែមលើកទី១")។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២")។ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់ ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D254/1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៣")។

[5] សំណុំរឿង០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D272 ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")។

[6] សំណុំរឿង០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D272/1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤")។

[7] សំណុំរឿង០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D281 ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង")។ *សូមមើលផងដែរ* សំណុំរឿង០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (សំណើកែតម្រូវ) ចុះថ្ងៃទី២៩ កុម្ភៈ ២០១៦ ឯកសារ D281/Corr-1។

[8] សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D302 ("សំណើសុំមតិយោបល់") កថាខណ្ឌ ៣ (អង្គហេតុទី ១៣) និងកថាខណ្ឌ ៩។

[9] ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D272/1/Corr-1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដែលមានការកែតម្រូវ")។



PRE-TRIAL CH... E.C.C.C

នឹងទំនប់កង្កួត[10] ដែលត្រូវបានទទួលយកដោយដីកាសម្រេចលើពាក្យសុំរបស់ ស.ច.ស.អ[11]។ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧ អនុលោមតាមការណែនាំរបស់អង្គជំនុំជម្រះ[12] មេធាវីការពារក្តីបានដាក់សំណើសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៧ ស.ព.អ បានដាក់ចម្លើយតបទៅនឹងសំណើសុំ[13] ដែលមេធាវីការពារក្តីបានឆ្លើយតបនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧[14]។

## III. ភាពទទួលយកបាន

6. សហមេធាវីបានលើកឡើងថា សំណើសុំ "អនុលោមតាមវិធាន ២១ និង ៧៦ នៃវិធានផ្ទៃក្នុង"[15] និងបានជំទាស់ថា កំហុសនីតិវិធីដែលត្រូវបានចោទប្រកាន់ ប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់សំណើក្នុងការទទួលព័ត៌មានពីសំណុំរឿងប្រឆាំងនឹងរូបគាត់ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារក្តី[16]។

7. វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង ណែនាំថា អង្គបុរេជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំ i) មិនបានបង្ហាញហេតុផលគ្រប់គ្រាន់ ii) មានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ iii) គ្មានមូលដ្ឋានច្បាស់លាស់។ ហេតុនេះ អង្គបុរេជំនុំជម្រះត្រូវរកឱ្យឃើញថា តើពាក្យសុំមោឃភាព (១) បានបញ្ជាក់ច្បាស់នូវផ្នែកនៃកិច្ចដំណើរការនីតិវិធី

---

[10] សំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D345។

[11] ដីកាសម្រេចលើពាក្យសុំ កថាខណ្ឌ ១៨។

[12] មន្ត្រីគ្រប់គ្រងសំណុំរឿង - ការជូនដំណឹង ការណែនាំរបស់អង្គបុរេជំនុំជម្រះ ដល់ភាគី តាមរយៈអ៊ីមេល សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៩)" ។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D345/1/3 ("ចម្លើយតប")។

[14] ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D345/1/5 ("ការឆ្លើយតប")។

[15] សំណើសុំ សេចក្តីផ្តើម។

[16] សំណើសុំ កថាខណ្ឌ ៦៤-៦៧។

ដែលមានព្យសនកម្មទៅលើសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬយ៉ាងណា[17] (២) បញ្ជាក់ច្បាស់នូវព្យសនកម្ម[18] និង (៣) ក្នុងករណីចាំបាច់ បន្ថែមភស្តុតាងឱ្យបានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចោទប្រកាន់[19]។

8. អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌនៅក្នុងវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ។ កិច្ចស៊ើបសួរដែលត្រូវបានជំទាស់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[20] និងបទចោទ[21] មិនពាក់ព័ន្ធដល់ដីកាបង្គាប់ណាមួយដែលបើកឱ្យប្តឹងឧទ្ធរណ៍នោះទេ។ ពុំមានចំណុចណាមួយនៅក្នុងសំណើសុំលើកឡើងថា ពុំមានមូលដ្ឋានលើអង្គហេតុ ឬអង្គច្បាប់ ដែលរារាំងសំណើសុំកុំឱ្យទទួល

---

[17] *សូមមើល* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ ៤១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D263/2/6 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ") កថាខណ្ឌ ២៤ ("ហេតុនេះ សំណើសុំធ្វើមោឃភាពត្រូវតែ [...] ជាក់លាក់ថា តើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយដែលមានកំហុសនីតិវិធី [...]")។

[18] *សូមមើល* សំណុំរឿង ០០២ (អបជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ឯកសារ D55/I/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ នួន ជា") កថាខណ្ឌ ៤០ ("ការបង្ហាញអំពីការរំលោភសិទ្ធិ [...] ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្កប់ជាកំហុសនីតិវិធី [...]។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកជាមោឃៈ") ៤២ ("ក្នុងករណីបទបញ្ញត្តិដែលពាក់ព័ន្ធមិនមានចែងអំពីមោឃភាពនៃកំហុសនីតិវិធី និងក្នុងករណី ICCPR មិនបានទទួលស្គាល់អំពីការរំលោភសិទ្ធិភាគីដែលដាក់ពាក្យសុំនឹងត្រូវបង្ហាញថា ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយសារកំហុសនីតិវិធី")។

[19] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣២។

[20] សូមមើល សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") (អបជ ២៦) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ [redacted] សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 កថាខណ្ឌ ៣១។

[21] *សូមមើល* សំណុំរឿង ០០៣ (អបជ ២៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលដាក់ [redacted] ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ឯកសារ D174/1/4 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦។

បានជោគជ័យនោះទេ។ អង្គជំនុំជម្រះយល់ឃើញបន្ថែមទៀតថា សំអាងហេតុដែលបានរៀបរាប់នៅក្នុងសំណើសុំមានភាពពេញលេញ ដោយសារវាមានសេចក្តីសន្និដ្ឋានស៊ីសង្វាក់សមហេតុផលដែលគាំទ្រដោយសំអាងហេតុតាមផ្លូវច្បាប់ ដែលមានរៀបរាប់នូវមូលដ្ឋានរបស់វា ឬដោយសម្ភារៈអង្គហេតុដែលបានបញ្ជាក់នៅក្នុងសំណុំរឿង។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា សំណើសុំអាចទទួលយកបាន។

## IV. ច្បាប់ជាធរមាន

9. មោឃភាពត្រូវបានកំណត់នៅក្នុងវិធាន ៤៨ នៃវិធានផ្ទៃក្នុង ដែលចែងថា "កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។

10. ហេតុនេះ ការពិនិត្យទៅលើសំណើសុំធ្វើមោឃភាពតម្រូវឱ្យមាន (១) ជាដំបូង ការពិចារណាលើកំហុសនីតិវិធី និង (២) បន្ទាប់មកទៀត អត្ថិភាពនៃការខូចខាតចំពោះម្ចាស់សំណើ ប្រសិនបើមានកំហុសនីតិវិធីមែន[22]។ ភាពមិនប្រក្រតីផ្នែកនីតិវិធីដែលមិនបង្កព្យសនកម្មដល់ម្ចាស់សំណើ មិនអាចត្រូវបានធ្វើមោឃភាពឡើយ[23]។

## V. ការពិចារណាលើអង្គសេចក្តី

11. បន្ទាប់ពីពិភាក្សារួចមក ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកបានមតិភាគច្រើនដើម្បីធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

---

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌ ៣៥។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (អបជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ឯកសារ D134/1/10 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ("សាលដីកាលើពាក្យសុំពីររបស់ [redacted]") កថាខណ្ឌ ២៥។

[23] សាលដីកាលើពាក្យសុំពីររបស់ [redacted] កថាខណ្ឌ ២៦ ដោយយោងទៅសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ២១។



PRE-TRIAL CHAMBER E.C.C.C.

12. ដូច្នេះ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះភាពអាចទទួលយកបាននៃសំណើនេះ មានបញ្ជាក់នៅក្នុងកថាខណ្ឌខាងមុខយ៉ាងណាក៏ដោយ ក៏មានការភ្ជាប់បន្ថែមមកជាមួយយោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ ទាក់ទិននឹងអង្គសេចក្តីនៃសំណើនេះតាមលក្ខខណ្ឌតម្រូវនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

## សេចក្តីសម្រេច

**ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយោងតាមសំឡេងឯកច្ឆន្ទៈ**

១. យល់ឃើញថាពាក្យសុំនេះអាចទទួលយកបាន។

២. ប្រកាស ថាអង្គជំនុំជម្រះមិនអាចរកសំឡេងគាំទ្រពីចៅក្រម៤(បួន)រូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។ អង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងគាំទ្រភាគច្រើន ដូច្នេះកិច្ចស៊ើបសួរដែលត្រូវបានសុំមោឃភាពនេះ ត្រូវតម្កល់ទុកជាបានការ។

**រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**PRAK Kimsan Olivier BEAUVALLET NEY Thol Kang Jin BAIK HUOT Vuthy**

ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និងចៅក្រមហួត វុទ្ធិ សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃពាក្យសុំ។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃពាក្យសុំ។

## យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី

13. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ (អបជ) នឹងបង្ហាញអំពីមតិយោបល់របស់ខ្លួនទាក់ទងនឹងសំណើរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរ និងដីកាសម្រេចទាក់ទងនឹងទំនប់កង្កត់។

14. ចៅក្រមជាតិនៃអបជ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

15. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថាមិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ[24]។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាតែបំពេញលក្ខខណ្ឌពីរគឺ ទី១.អង្គហេតុ "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់ជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ និងទី២. បុគ្គល "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[25]។

---

[24] មាត្រា ៤៤ និង១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[25] មាត្រា ១ នៃច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង

16. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នា ចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងសំណុំរឿង០០៤នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"[26] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់ចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ។[27]

17. ដូច្នេះបើទោះជាការលើកឡើងរបស់សហមេធាវីមិនត្រឹមត្រូវយ៉ាងណាក្តី ចៅក្រមជាតិនៃអបជសូមកត់សម្គាល់ថា សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៤ នេះដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត" ហើយចៅក្រមជាតិ និងអន្តរជាតិនៃអបជ ក៏បានខ្វែងយោបល់ចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិ នៃអបជ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ

18. តាមការយល់ឃើញខាងលើ ចៅក្រមជាតិនៃអបជ យល់ឃើញថា បើទោះជាកិច្ចស៊ើបសួរ មាន ឬមិនមានកំហុសនីតិវិធី ដែលនាំឲ្យរងនូវមោឃភាពក៏ដោយ ប៉ុន្តែដោយផ្អែកតាមការយល់ឃើញ

---

រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា

នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦(ក)។

[27] យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល, ចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ "[redacted] មិនមែនជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"។

ក្នុងកថាខណ្ឌខាងលើ រាល់កិច្ចស៊ើបសួរពាក់ព័ន្ធនឹងទំនប់កង្កួត និង ដីកាទាក់ទងនឹងទំនប់កង្កួត ត្រូវចាត់ទុកជាមោឃៈ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧

ប្រាក់ គីមសាន | ន័យ ថុល | ហួត វុទ្ធី

## យោបល់របស់ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK

19. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាព "លើអ្វីដែលទាក់ទងនឹងកិច្ចស៊ើបសួរលើទំនប់កង្ហត ដូចខាងក្រោម ១. កិច្ចស៊ើបសួរដែលបានធ្វើឡើង ចន្លោះពីពេលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដែលមានការកែតម្រូវ ៣. កិច្ចស៊ើបសួរដែលបានធ្វើបន្ទាប់ពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដោយមានការកែតម្រូវ ដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ៤. ដីកាចោទប្រកាន់លោក [redacted] ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តិនៅទំនប់កង្ហត ដូចមានកត់ត្រាក្នុង កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង"[28]។ ទឡ្ហីករណ៍នានាសម្រាប់សំណើទាំងនេះត្រូវបានបង្ហាញនៅក្រោមចំណងជើងចំនួនបួន រួមមាន ក-សាវតារពាក់ព័ន្ធ[29] ខ-សំណើសុំធ្វើមោឃភាពសម្ភារស៊ើបអង្កេតពាក់ព័ន្ធនឹងទំនប់កង្ហត[30] គ-សំណើសុំធ្វើមោឃភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដែលមានការកែតម្រូវ និងកិច្ចស៊ើបសួរដែលពាក់ព័ន្ធ[31] និង ឃ-សំណើសុំធ្វើមោឃភាពដីកាចោទប្រកាន់លោក [redacted] ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្ហត[32]។ ចៅក្រមដែលបានហត្ថលេខាសង្កេតឃើញថា សាវតារដែលបានបង្ហាញនៅក្នុងចំណងជើង "ក" ជាការបន្ថែមទៅលើទឡ្ហីករណ៍ដែលបាននៅក្នុងចំណងជើង "ខ" និង "ឃ" ជាក់លាក់ផ្សេងទៀត។ ចំណងជើងនីមួយៗក្នុងចំណោមចំណងជើងទាំងបីចុងក្រោយ មានមូលដ្ឋានមួយ ឬច្រើន។

[28] សំណើសុំ ទំព័រ ២០។

[29] សំណើសុំ កថាខណ្ឌ ២៧-៤៦។

[30] សំណើសុំ កថាខណ្ឌ ៤៧-៦៧។

[31] សំណើសុំ កថាខណ្ឌ ៦៨-៧១។

[32] សំណើសុំ កថាខណ្ឌ ៧២-៧៣។

## ក. សំណើសុំមោឃភាពសម្ភារ/វត្ថុស៊ើបអង្កេតដែលពាក់ព័ន្ធនឹងទំនប់កង្កួត

20. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះប្រកាសមោឃភាពកិច្ចស៊ើបសួរទាំងឡាយ ដែលពាក់ព័ន្ធនឹងទំនប់កង្កួត ដោយផ្អែកលើមូលដ្ឋានចំនួនប្រាំដូចខាងក្រោមនេះ i) "សហចៅក្រមស៊ើបអង្កេតមិនត្រូវបានបញ្ជូនឱ្យស៊ើបអង្កេតលើទំនប់កង្កួតទេ"[33] ii) "ភាពស្រពិចស្រពិលចាំបាច់ត្រូវដោះស្រាយ ជាប្រយោជន៍ដល់ជនត្រូវចោទ"[34] iii) "អ្នកស៊ើបអង្កេតអនុវត្តក្រៅពីវិសាលភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួស D219"[35] iv) "កិច្ចស៊ើបសួរដែលត្រូវបានរៀបរាប់ក្នុងរបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ បានរំលោភបំពានទៅលើវិធាន២៤ និងមានវិការនីតិវិធី"[36] និង v) "វិការៈនីតិវិធីបានបង្កជាព្យសនកម្មដល់ជនត្រូវចោទ"[37]។ ចៅក្រមដែលបានហត្ថលេខាត្រូវពិនិត្យមើលមូលដ្ឋាននីមួយៗដូចខាងក្រោមនេះ៖

### *i) តើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលសំណើសុំឱ្យស៊ើបអង្កេតលើទំនប់កង្កួតឬទេ*

### សារណា

21. សហមេធាវីសូមបញ្ជាក់ថា "ការស៊ើបអង្កេតទៅលើទំនប់កង្កួត ដែលធ្វើឡើងមុនពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដោយមានការកែតម្រូវ គឺជាវិការៈនីតិវិធី ព្រោះសហចៅក្រមស៊ើបអង្កេតមិនត្រូវបានបញ្ជូនឱ្យស៊ើបអង្កេតឡើយ"[38] និង "ហេតុដូច្នេះ កិច្ចស៊ើបអង្កេតដូចមាននៅក្នុងឧបសម្ព័ន្ធ ស្ថិតក្រៅការទទួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេត"[39]។ តាមការយល់ឃើញរបស់សហមេធាវី ទំនប់កង្កួតមិនត្រូវបានលើកឡើងទាល់តែសោះក្នុងដីកា

---

[33] សំណើសុំ កថាខណ្ឌ ៤៧-៥៣។

[34] សំណើសុំ កថាខណ្ឌ ៥៤-៥៥។

[35] សំណើសុំ កថាខណ្ឌ ៥៦-៥៨។

[36] សំណើសុំ កថាខណ្ឌ ៥៩-៦៣។

[37] សំណើសុំ កថាខណ្ឌ ៦៤-៦៧។

[38] សំណើសុំ កថាខណ្ឌ ៤៧។

[39] ដូចយោងខាងលើ។

01522680



សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣[40] ឬក្នុងតួសេចក្តីនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១ ទោះបីជាត្រូវបានលើកឡើងក្នុងជើងទំព័រនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១នោះក្តី ហើយ "ទំនប់កង្កួតមិនត្រូវបានកំណត់ ថាជាទីតាំងឧក្រិដ្ឋកម្ម*ដាច់ដោយឡែក* ដែលសហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតឡើយ"[41]។ លើសពីនេះទៅទៀត ទោះបីជា "ទំនប់កង្កួតត្រូវបានលើកឡើងនៅក្នុងអត្ថបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ"[42]ក៏ដោយ តាមសហមេធាវីកថាខណ្ឌទី១២ នៃអត្ថបទនេះ "បញ្ជាក់ច្បាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនមានបំណងបញ្ជូនឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតលើទំនប់កង្កួត ជាទីតាំងឧក្រិដ្ឋកម្ម*ដាច់ដោយឡែក* ពីទួលម្ទេសឡើយ"[43] ឬក៏ "ធ្វើការស៊ើបអង្កេតជាពិសេសទៅលើការរៀបការដោយបង្ខំ ឬអំពើហិង្សាលើយ៉េនឌ័រនៅទំនប់កង្កួតឡើយ"[44]។ សហមេធាវីបន្ថែមថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ៤ "មិនបានកំណត់ទំនប់កង្កួតថាជា- ទីតាំងឧក្រិដ្ឋកម្មមួយដែលស្ថិតក្រោមការស៊ើបអង្កេតឡើយ"[45]។ តាមការយល់ឃើញរបស់សហមេធាវី "លើកដំបូងដែលទំនប់កង្កួតត្រូវបានកំណត់ *ថាជាទីតាំងមួយដែលដាច់ចេញពីទួលម្ទេស ទាំងផ្នែកភូមិសាស្ត្រ និងអត្ថន័យ គឺនៅពេលដែល* [redacted] ត្រូវបានចោទប្រកាន់"[46] និងបន្ទាប់មក ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី៤ ដែលត្រូវបានកែតម្រូវ។[47]

22. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា "ទំនប់កង្កួតគឺជាផ្នែកនៃអង្គហេតុដែលបានលើកឡើងចោទប្រកាន់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយរបស់សពអ"[48] ដោយសារ

---

[40] សំណើសុំ កថាខណ្ឌ ៤៨។

[41] សំណើសុំ កថាខណ្ឌ ៤៩-៥០។

[42] សំណើសុំ កថាខណ្ឌ ៥១។

[43] ដូចយោងខាងលើ។

[44] ដូចយោងខាងលើ។

[45] សំណើសុំ កថាខណ្ឌ ៥២។

[46] សំណើសុំ កថាខណ្ឌ ៥៣។

[47] ដូចយោងខាងលើ។

[48] ចម្លើយតប កថាខណ្ឌ ៨-១៣។

ដីកាសន្និដ្ឋាននេះបានកំណត់យ៉ាងច្បាស់ថា "ទំនប់កង្កួតជាការដ្ឋានមួយកន្លែងដែលទាក់ទងនឹងទួលមេ្ទស ទីតាំង និងការប្រព្រឹត្តព្រហ្មទណ្ឌត្រូវបានលើកឡើងចោទប្រកាន់នៅទីនោះ"[49]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា គ្មានមូលហេតុដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរដែលរងការជំទាស់ "ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៣ តរៀងមក" ឡើយ ដោយសារ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយរបស់ សពអ ដែលបានប្ដឹង សចស ពីការលើកឡើងចោទប្រកាន់ទាក់ទងនឹងទំនប់កង្កួត ត្រូវបានដាក់ជិតពីរឆ្នាំមុនមកម្ល៉េះ គឺក្នុងខែកក្កដា ឆ្នាំ២០១១"[50]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា មេធាវីការពារក្ដីក៏បាន "បកស្រាយខុសចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីររបស់ សពអ និងចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់ កសចស"[51] និង "យល់ច្រឡំចំពោះគោលបំណងនៃឯកសារចោទប្រកាន់"[52]។ "អ្វីដែលជាបញ្ហា [សពអ ជំទាស់ថា] គឺថា សចសអ ត្រូវបានប្ដឹងអំពីអង្គហេតុទាំងឡាយនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅ [ទំនប់កង្កួត]។ បញ្ហាថាតើ សចស សម្រេចកំណត់ចរិកលក្ខណៈទំនប់កង្កួត ថាជាទីតាំងឧក្រិដ្ឋកម្មមួយដាច់ដោយឡែកពីទួលមេ្ទសដែរឬអត់ គឺមិនពាក់ព័ន្ធគ្នាទេ"[53]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការកែតម្រូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវបានដាក់ចូលក្នុងសំណុំរឿង ដើម្បីឆ្លុះបញ្ចាំងពីការបំភ្លឺដែលពាក់ព័ន្ធនឹងការគាំទ្រការចោទប្រកាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណី [redacted] ដែល "អាចត្រូវបានបកប្រែខុស" និង "ពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅវត្តមួយនៅជិត [ទំនប់កង្កួត]"[54]។

23. ក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីបានបញ្ជាក់ឡើងវិញពីទស្សនៈរបស់ខ្លួនថា ទំនប់កង្កួតមិនស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរទេ ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១ "មិន

[49] ចម្លើយតប កថាខណ្ឌ ៨-៩ យោងទៅរកដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ កថាខណ្ឌ៦ និងលេខយោង ១២ និង ១៣។

[50] ចម្លើយតប កថាខណ្ឌ ១៣។

[51] ចម្លើយតប កថាខណ្ឌ ២០-២៥។

[52] ចម្លើយតប កថាខណ្ឌ ២១។

[53] ចម្លើយតប កថាខណ្ឌ ២២។

[54] ចម្លើយតប កថាខណ្ឌ ២៤។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

បានភ្ជាប់ទំនប់កង្កួតទៅនឹងទួលម្នេសឡើយ"[55] ហើយជើងទំព័ររបស់វា "មិនបានបង្ហាញពីភាពច្បាស់លាស់ថាទំនប់កង្កួតកំពុងស្ថិតក្រោមកិច្ចស៊ើបអង្កេតឡើយ"[56] និងបន្ថែមថា កថាខណ្ឌទី៦របស់វា "អាចធ្វើការយោងទៅរកទំនប់ទឹក ឬអាងទឹក*ណាមួយ*"[57]។ សហមេធាវីបញ្ជាក់ថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ និងទី៤ និងសេចក្តីកែតម្រូវ មិនមែនជាដំណោះស្រាយចំពោះវិការៈនៃដំណើរការនីតិវិធីឡើយ[58]។ តាមទស្សនៈរបស់សហមេធាវី ការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅលើយោបល់ចៅក្រមអង្គបុរេជំនុំជម្រះ គឺមិនច្បាស់លាស់ទេ ដោយសារយោបល់ទាំងនោះ "មិនមែនជាសេចក្តីសម្រេចទេ"[59] ហើយយោបល់ក្នុងករណីនេះគឺផ្តោតលើវិធីសាស្រ្ត "មានលក្ខណៈជាក់លាក់ទៅនឹងអង្គហេតុ"[60]។

## ការពិភាក្សា

24. អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា វិសាលភាពនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតត្រូវបានកំណត់ដោយវិធាន ៥៣(១) និង(២), ៥៥(១) (២) និង(៣) នៃវិធានផ្ទៃក្នុង[61]។ វិធាន ៥៥(២) ចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកា

[55] ការឆ្លើយតប កថាខណ្ឌ ១៧។

[56] ការឆ្លើយតប កថាខណ្ឌ ៥។

[57] ការឆ្លើយតប កថាខណ្ឌ ៣។

[58] ការឆ្លើយតប កថាខណ្ឌ ១៦។

[59] ការឆ្លើយតប កថាខណ្ឌ ៩-១០។

[60] ការឆ្លើយតប កថាខណ្ឌ ១១។

[61] សេចក្តីសម្រេច នួន ជា កថាខណ្ឌ ១៦, សំណុំរឿង ០០១/១៨-៧-២០០៧-អវតក/កសចស ("រឿងក្តី ០០១") (អបជ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ("សេចក្តីសម្រេចឌុច") កថាខណ្ឌ ៣៥។ *ចូរអាន* វិធាន ៥៣(១) និង (២) នៃវិធានផ្ទៃក្នុងផងដែរ ត្រង់ផ្នែកពាក់ព័ន្ធដែលចែងថា៖ "(១) សហព្រះរាជអាជ្ញា [...] ត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត [...], (២) ដីកានេះ*ត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាង ដែលសហព្រះរាជអាជ្ញាមាន* [...]", វិធាន ២៥ (១) នៃវិធានផ្ទៃក្នុង ("ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ")។

សន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម”[62]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវបានរារាំងមិនឱ្យបើកការស៊ើបអង្កេតអង្គហេតុទាំងឡាយដែលមិនស្ថិតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ។ វិធាន ៥៥(៣) ចែងថា៖

“ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់។ កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា”[63]។

25. កាលពីមុនអង្គបុរេជំនុំជម្រះបានកត់សំគាល់ថា “សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការស៊ើបសួរលើអង្គហេតុទាំងអស់ដែលបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម”[64] និងសំខាន់ជាងនេះទៅទៀត ខ្លួនបានកត់សំគាល់ថា “សហចៅក្រមស៊ើបអង្កេតក៏ទទួលបាន*កាលៈទេសៈជុំវិញអំពើទាំងឡាយដែលរៀបរាប់នៅក្នុង*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម”[65]។ អង្គបុរេជំនុំជម្រះបានកំណត់និយមន័យកាលៈទេសៈជុំវិញទាំងនោះថាជា “កាលៈទេសៈដែលគេចោទថា *ឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើយ ហើយនាំដល់ការកំណត់បទចោទ*”[66]។ អង្គបុរេជំនុំជម្រះក៏បានកត់

[62] *សូមមើល* មាត្រា ១២៤(៣) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ (“ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ”។

[63] *សូមមើលផងដែរ* មាត្រា ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៨០ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង [ច្បាប់បកប្រែ] (“ចៅក្រមស៊ើបសួរអាចស៊ើបសួរតែអំពីអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់រដ្ឋអាជ្ញាតែប៉ុណ្ណោះ”)។

[64] សេចក្តីសម្រេច ឌុច កថាខណ្ឌ ៣៥។

[65] ដូចខាងលើ។

[66] ដូចខាងលើ។

សំគាល់បន្ថែមទៀតថា កាលៈទេសៈទាំងនោះ "មិនត្រូវបានគេយល់ឃើញថាជាអង្គហេតុថ្មីឡើយ។ ដូច្នេះហើយ កាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ"[67]។

26. មានតែការពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមជាបន្តបន្ទាប់ ព្រមទាំងការពិចារណាលើភស្តុតាងដែលជាឧបសម្ព័ន្ធ ដែលជាមូលដ្ឋាននៃសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាទេ ទើបអាចកំណត់ថាតើកិច្ចស៊ើបសួរជាបន្តបន្ទាប់ និងកិច្ចដែលរងការជំទាស់ ស្ថិតក្នុង ឬមិនស្ថិតក្នុងវិសាលភាពនៃបញ្ហាដែលត្រូវបានដាក់ចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើអនុវត្តក្រៅវិសាលភាព សុពលភាពនីតិវិធីនៃកិច្ចស៊ើបសួរនោះ អាចចោទជាបញ្ហា។

27. ករណីនេះបង្ហាញដោយខ្លួនឯងថា ដើម្បីឱ្យកិច្ចណាមួយស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ អំពើទាំងឡាយដែលគេអះអាងថាត្រូវបានប្រព្រឹត្តនៅការដ្ឋានទំនប់កង្កួត ត្រូវតែបង្កើតបានជាផ្នែកនៃអង្គហេតុដែលចោទប្រកាន់ ដែលផ្តួចផ្តើមដោយសហព្រះរាជអាជ្ញា។ ហេតុដូច្នេះ មុននឹងចេញសេចក្តីសម្រេចណាមួយ ចៅក្រមដែលបានហត្ថលេខាត្រូវតែធ្វើការពិនិត្យពិច័យដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់លើដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដើម្បីឱ្យប្រាកដថា ឬសម្រេចថា ទីតាំងនេះ ស្ថិតក្នុងទីតាំងនៃការប្រព្រឹត្តិបទល្មើស ដូចដែលកំណត់ដោយសហព្រះរាជអាជ្ញាអន្តរជាតិដែរឬទេ[68]។

---

[67] ដូចខាងលើ។

[68] សំណុំរឿង ០០៣/០៧-៩-២០០៩-អវតក/កសចស (អបជ២០), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនិងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ HARMON ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យនិងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 ("សាលដីកាលើសំណើចំនួនពីរសុំមោឃភាព") កថាខណ្ឌ ២០។ សំណុំរឿង ០០៤/០៧-៩-២០០៩-អវតក/កសចស (អបជ២៣), សេចក្តីពិចារណាលើសំណើរបស់ [redacted] សុំមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនិងវត្តតាមាក់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D263/1/5 កថាខណ្ឌ ៥៥។ សំណុំរឿង ០០៣/០៧-៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") (អបជ២៨), សាលដីកាពាក់ព័ន្ធទៅនឹង (១) បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើទាំង៩សុំដាក់សំណើសុំមោឃភាពជូន ជូនអង្គបុរេជំនុំជម្រះ និង (២) សំណើសុំមោឃភាពចំនួនពីរដែលយោងដោយសហចៅក្រម

28. ក្នុងករណីនេះ ចៅក្រមដែលបានហត្ថលេខា យល់ស្របជាមួយមេធាវីការពារក្តីថា ការដ្ឋានទំនប់កង្កួតមិនត្រូវបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣នោះទេ។

29. ទោះបីជាយ៉ាងណាក្តី ចៅក្រមដែលបានហត្ថលេខាបានរកឃើញថា ការចោទប្រកាន់ទាំងឡាយដែលបានធ្វើឡើងក្នុងកថាខណ្ឌ ៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ បានផ្អែកទៅលើការអះអាងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ដែលបាននិយាយថា "បងៗរបស់គាត់ត្រូវបានអង្គការបញ្ជូនទៅលើកទំនប់កង្កួត"[69]។ លើសពីនេះទៅ ទៀត ចៅក្រមដែលបានហត្ថលេខាសង្កេតឃើញថា ទំនប់កង្កួតក៏ត្រូវបានលើកឡើងក្នុងកថាខណ្ឌទី ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដដែលនោះដែរ ដែលមានខ្លឹមសារថា *"ទួលម្ទេសគឺជាការដ្ឋានមួយនៅក្បែរនោះ ដែលមានមនុស្សជាច្រើនត្រូវបានស្ថិតនៅក្រោមការធ្វើពលកម្មដោយបង្ខំ និងដែលត្រូវបានប្រើប្រាស់ធ្វើជាកន្លែងលត់ដំសម្រាប់ពួកកម្មាភិបាលតំបន់ ១ ដែលត្រូវបោសសម្អាត។ ទំនប់ទឹក និងអាងទឹកដ៏ធំមួយត្រូវបានគេសាងសង់នៅកន្លែងនេះ"*[70]។ ទំនប់ដែលត្រូវបានយោងក្នុងកថាខណ្ឌទី ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ គឺទំនប់កង្កួតដែលត្រូវបានដកស្រង់ឈ្មោះក្នុងភស្តុតាងទាំងឡាយដែលបានរាយនាមក្នុងជើងទំព័រ ១២ និង ១៣។ ក្នុងចំណោមនោះ ចម្លើយមួយមានខ្លឹមសារថា "ប្រាំខែក្រោយមក អង្គការបានបញ្ជូនខ្ញុំទៅទំនប់កង្កួតដែលស្ថិតក្នុងទួលម្ទេស ភ្នំអធិបតី ក្នុងស្រុកបាត់ដំបង"[71]។ ការចោទប្រកាន់អំពើល្មើសត្រង់កថាខណ្ឌទី៦ ក៏បានផ្អែកទៅលើចម្លើយរបស់[redacted] ដែលមានខ្លឹមសារថា "នៅពេលដែលគេចាប់ខ្លួនខ្ញុំ គេបានយកខ្ញុំទៅដាក់ក្នុងគុកបាណន់។ វាជា គុករបស់តំបន់១ (អ្នកស៊ើបអង្កេតសួររកទីតាំងជាក់លាក់)។ បច្ចុប្បន្ននេះ វាជាសាលាស្រុកបាណន់។ ខ្ញុំនៅទីនេះបានតែបីថ្ងៃ បន្ទាប់មកគេបានបញ្ជូនខ្ញុំទៅទួលម្ទេស ដែលជាកន្លែងលត់ដំ។

---

ស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D165/2/26 ("សេចក្តីសម្រេចលើសំណើទាំង៩") កថាខណ្ឌ ១៥៣, ១៩១។

[69] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ ជើងទំព័រទី៧ យោងទៅ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ D22/3106/1, ERN 00561504-00561505 (D65.1.8b)។

[70] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ កថាខណ្ឌ ៦។

[71] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ ជើងទំព័រទី១២ យោងទៅ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ D22/3882/1, ERN00571582។

ទួលម្ទេសជាការដ្ឋានដែលបែងចែកមនុស្សបីក្រុម។ មនុស្សពីរក្រុមមិនមែនជាអ្នកទោសទេ ពួកគេគ្រាន់តែត្រូវធ្វើការធ្ងន់។ កងរបស់ខ្ញុំ គឺកងទី៣ ដែលជាកងអ្នកទោស ក្រុមអ្នកទទួលការលត់ដំ គេហៅថា "កងពិសេស"។ ការដ្ឋាននេះស្ថិតនៅក្រោមការដ្ឋានទំនប់កង្កួត ភាគខាងលិចនៃភ្នំធិបតី"[72]។

30. ការិយាល័យសហព្រះរាជអាជ្ញាក៏បានដាក់បង្ហាញរបាយការណ៍កម្ពុជាប្រជាធិបតេយ្យមកពីតំបន់១ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ដែលមានខ្លឹមសារថា "[ទំនប់កង្កួត] ឡើងខ្ពស់បានជាង ១០ម៉ែត្រ ហើយៗកំពុងបន្តទៀត និងបន្តុបថ្មលើខ្នងទំនប់។ ឯទ្វារវិញកំពុងចាក់សរសរពុម្ពទី២បានពាក់កណ្តាលហើយ"[73]។ ផ្នែកពីរផ្សេងទៀតនៃរបាយការណ៍ដដែលនេះបង្ហាញពីដើមហេតុដែលនាំឱ្យសហព្រះរាជអាជ្ញាមានមូលហេតុក្នុងការជឿជាក់ថាមានទំនាក់ទំនងរវាងការដ្ឋាននោះ និងក្បាលម៉ាស៊ីនសន្តិសុខ។ ផ្នែកទី១មានខ្លឹមសារថា "នៅទ្វារទឹកកង្កួត ខ្មាំងវាលបដាក់ឈើក្នុងបេតុង [ក្នុងគោលបំណងបំផ្លាញទ្វារទឹក]។ ឈ្មោះ[redacted]។ ប្រវត្តិវាអ្នកគួរផ្តង់ផ្ទះថ្ម មកពីភ្នំពេញ។ ក្រោយរំដោះ ជម្លៀសមកនៅសហករណ៍ស្វាយជាតិ ស្រុកសង្កែ។ យើងខ្ញុំបានប្រគល់ឱ្យទៅសេនាធិការហើយ"[74]។ ផ្នែកទី២ មានខ្លឹមសារដូចតទៅនេះ៖ "នៅទំនប់កង្កួតនេះដែរ ឈ្មោះ[redacted] ប្រ.ជមូលដ្ឋាន មកពីសំរោងស្រុកគាស់ក្រឡ ដែលក្តាប់កម្លាំងប្រ.ជថ្មី ធ្វើទំនប់កង្កួតនេះ វាបំផុសឱ្យប្រជាជនរត់អស់ ១៥នាក់ [ចេញពីកន្លែងធ្វើការ] កាលពីថ្ងៃ ២៤-៥-១៩៧៧។ ទិសវាទៅថៃ។ យើងចាប់វាបាន ៤នាក់វិញ។ យើងកំពុងស្កាត់វាទៀត"[75]។

---

[72] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ ជើងទំព័រទី១២ យោងទៅ ការសម្ភាសន៍កសពអ របស់ [redacted] ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ៦ ដែលលេខយោង ១២ យោងទៅឯកសារ Dl.3.11.36, ERN 01384129 (FR), ERN 00210532 (EN)។

[73] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ កថាខណ្ឌ ៦ ដែលលេខយោង ១៣ យោងទៅឯកសារ D1.3.10.2, ERN 00143567-69។

[74] ដូចយោងខាងលើ ERN00143567។

[75] ដូចយោងខាងលើ។

01522687



31. ចៅក្រមដែលបានហត្ថលេខាសន្និដ្ឋានថា នៅពេលដែលសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ ទំនប់កង្កួតត្រូវបានបញ្ចូលក្នុងវិសាលភាពនៃការចោទប្រកាន់លើអំពើល្មើស ដែលពាក់ព័ន្ធទៅនឹងការដ្ឋានទួលម្ទេស។

32. ចៅក្រមដែលបានហត្ថលេខាសូមគូសបញ្ជាក់បន្ថែមទៀតថា ចាប់ពីពេលនោះមក សហព្រះរាជអាជ្ញាអន្តរជាតិបានបំភ្លឺ ត្រង់កថាខណ្ឌទី១២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ថា "ការចាប់ខ្លួន ការសម្លាប់ និង*ឧក្រិដ្ឋកម្មដទៃទៀត* ដែលបានប្រព្រឹត្តឡើងនៅទីតាំងទំនប់កង្កួតនៅក្នុងសម័យកាលដែលដែល [redacted] បានធ្វើជាលេខាតំបន់១ គឺមានបំណងដើម្បីបញ្ចូលទៅក្នុងកិច្ចស៊ើបសួរដែលកំពុងតែធ្វើ នូវការដ្ឋានទួលម្ទេស មន្ទីរសន្តិសុខតំបន់១ និងការបោសសម្អាតភូមិភាគពាយ័ព្យ"[76]។ ការបំភ្លឺនេះពាក់ព័ន្ធទៅនឹងកថាខណ្ឌប្រាំដល់ប្រាំបីនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី ១ ដោយគ្មានភាពស្រពិចស្រពិលអ្វីទេ។

33. ចៅក្រមដែលបានហត្ថលេខាពិចារណាថា ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ កំណត់កាលបរិច្ឆេទមុនកិច្ចស៊ើបសួរដែលរងការជំទាស់[77] ដូច្នេះ គ្មានមូលដ្ឋានណាមួយសម្រាប់មោឃភាពកិច្ចស៊ើបសួរទាំងនោះ ដោយផ្អែកលើមូលដ្ឋានថា កិច្ចទាំងនោះស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរឡើយ។

34. ហេតុដូច្នេះ ចៅក្រមដែលបានហត្ថលេខារកឃើញថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះមិនសមស្របទេ។

***ii) ថាតើករណីមានភាពមិនច្បាស់លាស់ តុលាការត្រូវដោះស្រាយដោយផ្តល់ជាប្រយោជន៍របស់ជនត្រូវចោទ***

---

[76] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ កថាខណ្ឌ ១២។

[77] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ចំណែកឯឧបសម្ព័ន្ធនៃសំណើសុំយោងទៅរកតែកិច្ចស៊ើបសួរចុះខែកុម្ភៈ ឆ្នាំ២០១៣ តទៅ។



E.C.C.C. PRE-TRIAL CHAMBER

# សារណា

35. សហមេធាវីបានលើកឡើងថា "មានភាពមិនច្បាស់ខ្លាំងពាក់ព័ន្ធទៅនឹងទីតាំងនៃកន្លែងទាំងពីរ"[78] គឺទួលមេ្ទស និងទំនប់កង្កួត ហើយដើម្បីការពារសិទ្ធិជនត្រូវចោទ "ភាពស្រពិចស្រពិលចាំបាច់ត្រូវដោះស្រាយ ជាប្រយោជន៍ដល់ជនត្រូវចោទ"[79]។ អនុលោមតាមសហមេធាវី ដោយពិនិត្យទៅលើ "ការតម្រូវឱ្យដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលជាក់លាក់ និងលម្អិតគ្រប់គ្រាន់" [80] នោះ "គឺមិនគ្រប់គ្រាន់ឡើយ ដែលលើកឡើងថា ការស៊ើបអង្កេតនេះអាចបញ្ជូនទៅក្នុងការស៊ើបអង្កេតពីទួលមេ្ទស"[81]។

36. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា កម្រិតនៃភាពជាក់លាក់ដែលលើកឡើងក្នុងដីកាសន្និដ្ឋានគឺស្របទៅតាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង និងលើសពីលក្ខខណ្ឌដែលតម្រូវដោយទម្លាប់អនុវត្តរបស់អង្គបុរេជំនុំជម្រះ[82]។

37. សហមេធាវីបានឆ្លើយតបថា "ស.ព.អ បកស្រាយដោយភាន់ច្រឡំលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាក់ទងនឹងភាពជាក់លាក់"[83] និងបានបំភ្លឺថា "សំណើនេះមានការពាក់ព័ន្ធនឹងការខកខានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [របស់ ស.ព.អ] ក្នុងការកំណត់ពីការចោទប្រកាន់ច្បាស់លាស់អំពីឧក្រិដ្ឋកម្មតាមរយៈព្រំប្រទល់ភូមិសាស្ត្រដែលត្រូវបានរឹតត្បិត"[84] និងបំភ្លឺថា "មេធាវីការពារក្តីមិនបានស្នើឱ្យ [...]សហព្រះរាជអាជ្ញាគួរត្រូវបានតម្រូវឱ្យកំណត់អត្តសញ្ញាណពីកន្លែងនីមួយៗឱ្យជាក់លាក់"[85]។

---

[78] សំណើសុំ កថាខណ្ឌ ៥៥។

[79] សំណើសុំ កថាខណ្ឌ ៥៤-៥៥ ដែលយោងក្នុងលេខយោង ៥៩ ទៅគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជាប់ចោទ*។

[80] សំណើសុំ កថាខណ្ឌ ៥៤ បានយោងទៅវិធាន ៥៣(៣)។

[81] សំណើសុំ កថាខណ្ឌ ៥៤។

[82] ចម្លើយតប កថាខណ្ឌ ១១-១២ យោងទៅវិធាន ៥៣ នៃវិធានផ្ទៃក្នុងនិងយបល់ចៅក្រមនៃអង្គបុរេជំនុំជម្រះ។

[83] ការឆ្លើយតប កថាខណ្ឌ ៦-៧។

[84] ការឆ្លើយតប កថាខណ្ឌ ៦។

[85] ការឆ្លើយតប កថាខណ្ឌ ៧។

**ការពិភាក្សា**

38. ទី១ ចៅក្រមដែលបានហត្ថលេខាកត់សំគាល់ថា សហមេធាវីមិនបានតវ៉ាថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ត្រូវតែកំណត់អត្តសញ្ញាណគ្រប់ទីតាំងជាក់លាក់ដែលបទឧក្រិដ្ឋបានកើតឡើងទេ។ ទី២ អង្គជំនុំជម្រះសូមរម្លឹកថា ខ្លួនបានកំណត់រួចហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលកិច្ចស៊ើបសួរលើបទឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្កួតតាមយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១[86]។ ចំពោះទឡ្ហីករណ៍របស់សហមេធាវីថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ បានបំពានលើសិទ្ធិជនត្រូវចោទ ដោយសារដីកាសន្និដ្ឋានទាំងនោះមិនបាន "ចែងឱ្យបាន*ច្បាស់លាស់* ពីការចោទប្រកាន់ព្រហ្មទណ្ឌ*ដែលភ្ជាប់ទៅនឹងព្រំដែនភូមិសាស្ត្រមានកម្រិត*" អង្គបុរេជំនុំ ជម្រះសូមរម្លឹកថា វិធាន ៥៣ នៃវិធានផ្ទៃក្នុងបានបញ្ញត្តិដូចខាងក្រោមនេះ៖

"១. ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន។ ដីកានេះ ត្រូវមានព័ត៌មានដូចខាងក្រោម៖

ក-សេចក្តីសង្ខេបអំពីអង្គហេតុ

ខ-ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់

គ-បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ

ឃ-ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន

ង-កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ។

២. ដីកានេះត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀត ដែលបានចាត់ទុកជាភស្តុតាង ដែល

---

[86] សូមមើលខ្លឹមសារខាងលើ កថាខណ្ឌ ៣១។

សហព្រះរាជអាជ្ញាមាន រួមទាំងអ្វីៗទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភស្តុតាងដោះបន្ទុកផងដែរ។

៣. អវត្តមានផ្នែកណាមួយនៃទម្រង់ការខាងលើនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដូចមានចែងក្នុងអនុវិធាន ១ ត្រូវចាត់ទុកជាមោឃៈ។"

39. ចៅក្រមដែលបានហត្ថលេខាសង្កេតឃើញថាវិធាន ៥៣(១)(ក)(ខ)នៃវិធានផ្ទៃក្នុងតម្រូវឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចែងតែ *សេចក្តីសង្ខេប* អំពីអង្គហេតុ និងប្រភេទបទ ល្មើសដែលបានចោទប្រកាន់។ នៅក្នុងវិធាន ៥៣ គ្មានលក្ខខណ្ឌដែលតម្រូវឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ត្រូវតែចែងឱ្យបានច្បាស់លាស់ពីការចោទប្រកាន់ព្រហ្មទណ្ឌ "ដោយភ្ជាប់ទៅនិងព្រំដែនភូមិសាស្ត្រមានកម្រិត" ដូចដែលសហមេធាវីបានអះអាងទេ។ ចំពោះសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានភាពច្បាស់លាស់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចៅក្រមដែលបានហត្ថលេខាបានយល់ពីខាងដើមថា *កង្វះអង្គហេតុពិស្តារ* ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ *មិន "រាប់ថាជាការខ្វះការជូនដំណឹងនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះឡើយ"*[87]។ លើសពីនេះទៅទៀត "ដើម្បីឱ្យជនត្រូវចោទអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ *លក្ខខណ្ឌកំណត់ស្តីពីការជូនដំណឹងត្រូវអនុវត្តចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងកម្រិតខ្លះ*"។ ទោះបីជាយ៉ាងណាក៏ដោយ *កម្រិតនៃលក្ខណៈពិសេស ដែលបានទាមទារនៅក្នុងដីកាចោទប្រកាន់មិនអាចត្រូវបានទទួលស្គាល់ដោយផ្ទាល់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ពីព្រោះ ក.ស.ព. ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយមិនបានទទួលប្រយោជន៍ពីកិច្ចស៊ើបសួរទាំងមូលនោះទេ"*[88]។

---

[87] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម សំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែឧសភា ឯកសារ D97/15/9 ("សាលដីកាសហឧក្រិដ្ឋកម្មរួម") កថាខណ្ឌទី ៩៥ យោងទៅរកយុត្តិសាស្ត្រអន្តរជាតិ។

[88] ដូចយោងខាងលើ។

40. បន្ទាប់ពីការវិភាគដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដូចបានពន្យល់ខាងលើ ចៅក្រមដែលបានហត្ថលេខា យល់ឃើញថា គ្មានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងបញ្ហាថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួល ឬមិនបានទទួលកិច្ចស៊ើបសួរលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្កួតឡើយ[89]។

41. អាស្រ័យហេតុនេះ សំណើនេះគប្បីត្រូវបដិសេធតាមសំអាងហេតុដូចពោលខាងលើ។

### *iii) តើអ្នកស៊ើបអង្កេតបានអនុវត្តក្រៅពីវិសាលភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួស D219 ឬទេ*

### សារណា

42. សហមេធាវីអះអាងថា "កិច្ចស៊ើបសួរដែលបានធ្វើឡើង ផ្អែកលើដីកាចាត់ឲ្យស៊ើបសួរជំនួស [D219] *ដែលមានបំណងស៊ើបអង្កេតឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅទំនប់កង្កួត ថាជាទីតាំងដាច់ដោយឡែកពីទួលម្នេស* គឺស្ថិតក្រៅការទទួលខុសត្រូវរបស់ខ្លួន ហើយត្រូវបានបំពេញ ដោយមិនមានអំណាចប្រតិភូកម្មពីចៅក្រមឡើយ"[90] ពីព្រោះវិធាន ៦២ នៃវិធានផ្ទៃក្នុងបានចែងច្បាស់ថា "ដីកាចាត់ឲ្យស៊ើបសួរជំនួស *មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ*"[91] ហើយដីកាចាត់ឲ្យស៊ើបសួរជំនួស D219 "កំណត់ច្បាស់ថា ទីតាំងភូមិសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានណត់សម្រាប់កិច្ចស៊ើបសួរ រួមទាំង [...] ទួលម្នេស"[92] ហើយ "រហូតមកដល់ពេលនេះ មិនមានការកែប្រែណាមួយ ដើម្បីពង្រីកវិសាលភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួសដើម្បីបញ្ចូលកិច្ចស៊ើបសួរទៅលើទំនប់កង្កួត ដោយយោងទៅតាមវិធាន ៦២ នៃវិធានផ្ទៃក្នុង"[93]។

43. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា "អ្នកស៊ើបអង្កេត កសចស បានបំពេញការងាររបស់ខ្លួនក្នុងវិសាលភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួសដែលពាក់ព័ន្ធ"[94] និងបានអះអាងថា មេធាវី

[89] សូមមើលខ្លឹមសារខាងលើ កថាខណ្ឌ ២៨-៣១។

[90] សំណើសុំ កថាខណ្ឌ ៥៨។

[91] សំណើសុំ កថាខណ្ឌ ៥៦។

[92] សំណើសុំ កថាខណ្ឌ ៥៧។

[93] សំណើសុំ កថាខណ្ឌ ៥៨។

[94] ចម្លើយតប កថាខណ្ឌ ១៤-១៩។

01522692



ការពារក្ដី "មានកំហុសឆ្គងនៅពេលគាត់ឱ្យដឹងថា អ្នកស៊ើបអង្កេត កសចស មិនត្រូវបានប្រគល់អាណត្តិនៃសិទ្ធិអំណាច ដើម្បីដឹកនាំកិច្ចស៊ើបសួរទៅលើ [ទំនប់កង្កូត] វៀរលែងតែវាត្រូវបានបញ្ជាក់ឈ្មោះចំៗនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស"[95]។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានកត់សំគាល់ផងដែរថា កិច្ចស៊ើបសួរមួយចំនួនដែលរងការជំទាស់ "ត្រូវបានដឹកនាំធ្វើឡើងដោយអនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ឯកសារលេខ D118 [ដែល] គ្របដណ្ដប់យ៉ាងច្បាស់អំពីកិច្ចស៊ើបសួរទៅលើ [ទំនប់កង្កូត]"[96] និងបានកត់សំគាល់ថា "ខ្លឹមសារនៃដីកាចាត់ឱ្យស៊ើបសួរជំនួស [D219] បានដាក់បញ្ចូល [...] ទួលម្ទេសយ៉ាងច្បាស់"[97]។ សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ថា "បើយកតាមសនិទានកម្មរបស់ [មេធាវីការពារក្ដី] ដែលថាទីតាំងឧក្រិដ្ឋកម្មនីមួយៗដែលជាទីកន្លែងដែលឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ ត្រូវកំណត់ឈ្មោះនីមួយៗនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះ នឹងបង្កឱ្យមានលទ្ធផលគួរឱ្យអស់សំណើចជាមិនខាន"[98] និងបានអះអាងថា "ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ [...] គឺបានប្រព្រឹត្តឡើងក្នុងលក្ខណៈរីករាលដាល និងជាប្រព័ន្ធ"[99]។ សហព្រះរាជអាជ្ញាអន្តរជាតិបានរម្លឹកថា "ឱ្យតែកាលៈទេសៈនានា ដែលបានលេចឡើងនៅក្នុងពេលនៃដំណើរការនៃការស្ដាប់ចម្លើយសាក្សីដែលបានដឹកនាំធ្វើ អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅតែជាប់ទាក់ទងទៅនឹងអង្គហេតុនានា ដូចដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺប្រាកដណាថា វាស្ថិតក្នុងបញ្ហានានាដែលបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត"[100]។

44. សហមេធាវីបានឆ្លើយតបថា "ស.ព.អ បដិសេធមិនទទួលស្គាល់ពីកង្វះព័ត៌មានអំពី [ទំនប់កង្កូត] ក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសឯកសារ D118 និងឯកសារ D219"[101]។ សហមេធាវីបានអះអាងឡើងវិញថា "នៅពេលចេញ [ដីកាចាត់ឱ្យស៊ើបសួរជំនួសទាំងនេះ] ស.ច.ស មិនបានទទួលកិច្ច

---

[95] ចម្លើយតប កថាខណ្ឌ ១៦។

[96] ចម្លើយតប កថាខណ្ឌ ១៤-១៥ យោងទៅរកដីកាចាត់ឱ្យស៊ើបសួរជំនួស D118 ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ២។

[97] ចម្លើយតប កថាខណ្ឌ ១៦ យោងទៅរកដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤។

[98] ចម្លើយតប កថាខណ្ឌ ១៨។

[99] ដូចយោងខាងលើ។

[100] ចម្លើយតប កថាខណ្ឌ ១៩។

[101] ការឆ្លើយតប កថាខណ្ឌ ១២-១៤។

ស៊ើបសួរលើទំនប់កង្កតនោះទេ"[102] ហើយសហមេធាវីអះអាងថា ដីកាចាត់ឱ្យ ស៊ើបសួរជំនួស "មិនអាចពង្រីកកិច្ចស៊ើបសួរដើម្បីបញ្ចូលទំនប់កង្កតបានទេ"[103] និង "ការយោងទៅដល់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅទួលម្នេស មិនទាក់ទងដោយផ្ទាល់ជាមួយទំនប់កង្កត ឬបញ្ជាក់ពីទំនប់ទំនប់កង្កតច្បាស់លាស់ឡើយ"[104]។

## ការពិភាក្សា

45. បញ្ហាទី១ ចៅក្រមដែលបានហត្ថលេខាសូមរម្លឹកថា អង្គជំនុំជម្រះបានលើកឡើងរួចហើយថា ទំនប់កង្កតត្រូវ បានបញ្ចូលទៅក្នុងវិសាលភាព នៃកិច្ចស៊ើបសួរការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌទាំងឡាយដែលទាក់ទងទៅនឹងការដ្ឋានទួលម្នេស[105]។ សហព្រះរាជអាជ្ញាក៏បានកត់សំគាល់ផងដែរថា ក្នុងកាលៈទេសៈជាច្រើនដែលលេចឡើងក្នុងដំណើរការសម្ភាសន៍សាក្សី ដែលត្រូវបានធ្វើឡើងតាមដីកាចាត់ឱ្យស៊ើបសួរជំនួស *នៅតែទាក់ទងទៅនឹងអង្គហេតុដែលបានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* ហើយវាស្ថិតនៅក្នុងបញ្ហាដែលត្រូវបានដាក់ចំពោះមុខសហចៅក្រមស៊ើប អង្កេតយ៉ាងពិតប្រាកដ។

46. ទាក់ទងនឹងទឡ្ហីករណ៍របស់សហមេធាវីថា អ្នកស៊ើបអង្កេតបានអនុវត្តកិច្ចស៊ើបសួរក្រៅពី*អំណាចដែលបានផ្ទេរ* "ដោយសារ [ទំនប់កង្កត] *មិនត្រូវបានចែងជាក់លាក់ក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស* D118 និង D219" ចៅក្រមដែលបានហត្ថលេខា យោងទៅបទប្បញ្ញត្តិនៃវិធាន ៦២ នៃវិធានផ្ទៃក្នុងដែលចែងថា៖

> "១. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមានអំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ។

[102] ការឆ្លើយតប កថាខណ្ឌ ១២។

[103] ដូចយោងខាងលើ។

[104] ការឆ្លើយតប កថាខណ្ឌ ១៤។

[105] សូមមើលខ្លឹមសារខាងលើ កថាខណ្ឌ ៣១។

២. *ដីកាចាត់ឱ្យស៊ើបសួរជំនួស មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ តែត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ និងដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬជាមួយនឹងបទល្មើសដែលកំពុងស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ពេលវេលាដែលត្រូវអនុវត្តក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស* ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះហត្ថលេខា និងកាលបរិច្ឆេទដោយសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតអាចដកនូវដីកាចាត់ឱ្យស៊ើបសួរជំនួសនេះមកវិញនៅពេលណាក៏បាន។"

47. ចៅក្រមដែលបានហត្ថលេខាសង្កេតឃើញថា មានតែលក្ខខណ្ឌតម្រូវ ដែលចែងដោយវិធាន ៦២ ទេ ដែលពាក់ព័ន្ធនឹង ភាពច្បាស់លាស់ពី "*ចរិតលក្ខណៈ* នៃកិច្ចស៊ើបសួរ" ដែលត្រូវតែទាក់ទងដោយផ្ទាល់ទៅនឹង*បទឧក្រិដ្ឋ* ដែលស្ថិតក្រោមការស៊ើបអង្កេត" និង *រយៈពេលកំណត់* សម្រាប់គោរពតាមដីកាចាត់ឱ្យស៊ើបសួរជំនួស។ យើងត្រូវអានប្រយោគទី១នៃវិធាន ៦២(២) ដែលចែងថា "ដីកាចាត់ឱ្យស៊ើបសួរជំនួស មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ" គួបជាមួយបញ្ញត្តិទាំងអស់នៃកថាខណ្ឌនេះ ហើយមិនអាចត្រូវបានបកស្រាយដើម្បីបន្ថែមលក្ខខណ្ឌដែលគ្មានចែង "ឱ្យមានភាពច្បាស់លាស់អំពីទីតាំងភូមិសាស្ត្រដែលត្រូវរងការស៊ើបអង្កេត" ដូចដែលសហមេធាវីបានអះអាងនោះទេ។

48. ម្យ៉ាងវិញទៀត ការហាមឃាត់មិនឱ្យសរសេរដីកាចាត់ឱ្យស៊ើបសួរជំនួសជាទម្រង់ទូទៅ មានចេតនាធានាឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតដឹកនាំ ដោយផ្ទាល់ ឬតាមរយៈអ្នកទទួលសិទ្ធិបំពេញកិច្ចក្រោមការត្រួតពិនិត្យរបស់ខ្លួន នូវកិច្ចស៊ើបសួរទាំងឡាយដែលស្ថិតក្នុងវិសាលភាព។ អង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការធ្វើវិសោធនកម្មលើដីកាចាត់ឱ្យស៊ើបសួរជំនួស ពីពេលមួយទៅពេលមួយ មិនមែនមានន័យថាសហចៅក្រមនោះ *ដាក់កម្រិតព្រំដែន* ទៅលើទីតាំងភូមិសាស្ត្រដែលរងការស៊ើបអង្កេតទេ ហើយសំខាន់ជាងនេះទៅទៀត សហចៅក្រមនោះមិនបានដាក់បញ្ចូលលក្ខខណ្ឌតម្រូវថ្មីណាមួយតាមវិធាន ៦២ ឡើយ។ ការអនុវត្តបែបនេះជាការចង្អុលបង្ហាញថា សហចៅក្រមរូបនេះកំពុងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការដឹកនាំកិច្ចស៊ើបសួរ អនុលោមទៅតាមវិធាន ៦២ តែប៉ុណ្ណោះ។

49. នៅក្នុងករណីនេះ ចៅក្រមដែលបានហត្ថលេខាកត់សំគាល់ថា ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ជាបឋមបានណែនាំឱ្យអ្នកស៊ើបអង្កេតឱ្យ "ក. រៀបចំ ឬបំពេញកំណត់ត្រាស្តីពីការកំណត់អត្តសញ្ញាណដែលមានស្រាប់ ដោយបញ្ជាក់ពីទីតាំងច្បាស់លាស់ និងអធិប្បាយអំពីចរិតលក្ខណៈនៃទីកន្លែងនីមួយៗដែលបានចុះក្នុងឧបសម្ព័ន្ធ *និងទីកន្លែងទាំងអស់ដែលពាក់ព័ន្ធនឹង ឬទាក់ទងទៅនឹងទីកន្លែង និងស្ថានភាពអង្គហេតុទាំងអស់* ដែលបានយោងក្នុងឧបសម្ព័ន្ធ[106]។ បន្ទាប់មកដីកានេះណែនាំឱ្យអ្នកស៊ើបអង្កេត "ខ. អនុវត្តរាល់ការវាស់វែង តាមរយៈរូបភាព GPS ឬជាទម្រង់លើក្រដាស ឬនីជិតថល ដែលចាំបាច់ក្នុងការបញ្ជាក់ពីទីតាំងនៃទីកន្លែងទាំងឡាយដែលបានយោងក្នុងឧបសម្ព័ន្ធ *និងទីកន្លែងទាំងអស់ដែលពាក់ព័ន្ធនឹង ឬទាក់ទងទៅនឹងទីកន្លែង និងស្ថានភាពអង្គហេតុទាំងអស់* ដែលបានយោងក្នុងឧបសម្ព័ន្ធ[107]។ ដោយសារការដ្ឋានទួលម្ទេសត្រូវបានរាយនាមយ៉ាងច្បាស់នៅ ក្នុងឧបសម្ព័ន្ធនៃដីកាចាត់ឱ្យស៊ើបសួរជំនួស D219[108] នោះចៅក្រមដែលបានហត្ថលេខាយល់ឃើញថា អ្នកស៊ើបអង្កេតត្រូវបានណែនាំយ៉ាងច្បាស់ឱ្យពិនិត្យទំនប់កង្កួតជាទីកន្លែង "ដែលជាប់ពាក់ព័ន្ធ ឬទាក់ ទងទៅនឹងទីកន្លែង និងស្ថានភាពអង្គហេតុទាំងអស់ ដែលបានយោងក្នុងឧបសម្ព័ន្ធ"។

50. ហេតុដូច្នេះ ចៅក្រមដែលបានហត្ថលេខាសន្និដ្ឋានថា កិច្ចស៊ើបសួរលើទំនប់កង្កួត ត្រូវបានធ្វើឡើងក្នុងវង្វង់សិទ្ធិអំណាចដែលបានផ្ទេរក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស D219។

51. អាស្រ័យហេតុនេះ ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា មូលដ្ឋានក្នុងការធ្វើមោឃភាពមិនសមស្របឡើយ។

***iv) ថាតើកិច្ចស៊ើបសួរដែលបានពណ៌នានៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ បានរំលោភបំពានវិធាន ២៤ នៃវិធានផ្ទៃក្នុង ហើយមានវិការៈផ្នែកនីតិវិធីដែរឬទេ***

---

[106] ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤, ("ដីកាចាត់ឱ្យស៊ើបសួរជំនួស D219") ទំព័រ ២។

[107] ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ទំព័រ ២។

[108] ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ឧបសម្ព័ន្ធ ទំព័រ ២។

## សារណា

52. សហមេធាវីលើកឡើងថា កិច្ចស៊ើបសួរដែលបានពណ៌នានៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរ[109] ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ដែល "ត្រូវបានធ្វើឡើងដោយអនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស លេខ D219" និងសម្ភារភស្តុតាងដែលជាលទ្ធផល ដូចជា ការរៀបការដោយបង្ខំចំនួន១៥គូ ដែលត្រូវបានធ្វើឡើងនៅទំនប់កង្កួត មានវិការៈផ្នែកនីតិវិធី និងបំពានលើតម្រូវការនៃវិធាន ២៥[110] នៃវិធានផ្ទៃក្នុង ដោយហេតុថា "ការសួរ [redacted] អំពីទីតាំងនៃការចោទប្រកាន់ពីការរៀបការដោយបង្ខំនេះ មានតម្លៃស្មើនឹងការសម្ភាសន៍[111]" "មិនមានការស្នើឡើងណាមួយថា កិច្ចសន្ទនានេះ [...] បានធ្វើឡើង [...] ក្រោមសម្បថ[112] ហើយដោយសារមិនមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនេះ "មិនមានមធ្យោបាយណាមួយដើម្បីសម្រេចថា តើសាក្សីត្រូវបានសួរសំណួរបើក [...] ឬសំណួរនាំមុខ[113] "មិនមានវិធីណាដើម្បីបញ្ជាក់ថា បុគ្គលដែលបានឆ្លើយ គឺពិតជា [សាក្សីដែលត្រូវលើកឡើងនេះ][114] ហើយដោយហេតុថា កិច្ចសន្ទនានោះកើតឡើង ៦ ឆ្នាំ ក្រោយពេលដែលសាក្សីបានផ្តល់ព័ត៌មានដែលត្រូវបានកត់ត្រាទុក នៅខណៈដែលសាក្សីបានបញ្ជាក់ច្បាស់ថាគាត់មានបញ្ហាចងចាំ[115]។

53. សពអ ដំបូង បានឆ្លើយតបថា ក្រុមមេធាវីការពារក្តី "មានកំហុសលើការបញ្ជាក់របស់ កសចស អំពីភស្តុតាង*ដែលមានស្រាប់* ទៅនឹងកិច្ចសម្ភាសន៍"[116] ហើយទីពីរ បានរម្លឹកថា កំណត់ហេតុដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត កសចស មាន "សច្ចធារណ៍នៃការទទួលខុសត្រូវ"[117] និងទីបី សពអ លើកឡើងថា ទោះក្នុងករណីណាក៏ដោយ រឿងនេះលែងជាបញ្ហាទៀតហើយ ដោយ

---

[109] កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ D219/647 ("WRIA D219/647") ទំព័រ២។

[110] សំណើសុំ កថាខណ្ឌ ៥៩-៦៣។ ចូរអានផងដែរ សំណើសុំ កថាខណ្ឌ ៤៣-៤៥ ដែលយោងទៅរក WRIA D219/647។

[111] សំណើសុំ កថាខណ្ឌ ៥៩។

[112] សំណើសុំ កថាខណ្ឌ ៦០។

[113] សំណើសុំ កថាខណ្ឌ ៦១។

[114] ដូចយោងខាងលើ។

[115] សំណើសុំ កថាខណ្ឌ ៦២។

[116] ចម្លើយតប កថាខណ្ឌ ២៥។

[117] ដូចយោងខាងលើ។

សចសអ "បានថ្លែងថា គាត់នឹងមិនតាមក្នុងរឿងចោទប្រកាន់ទាក់ទងនឹងការបំភ្លឹកស្តុកាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នេះ"[118]។

54. សហមេធាវី ឆ្លើយតបថា "សចសអ បានរក្សាសិទ្ធិក្នុងការបន្តការស៊ើបអង្កេតលើការចោទប្រកាន់របស់ [[redacted]]"[119] ហើយថា "នេះបញ្ជាក់ឱ្យឃើញច្បាស់តាមរយៈការពិភាក្សារបស់ សចសអ គាត់មានចេតនាលែងបន្តការស៊ើបអង្កេតរបស់គាត់ទៅលើអង្គហេតុជាក់លាក់មួយនេះ ជាជាងលើការចោទប្រកាន់ទាំងអស់ដែលត្រូវបានកំណត់"[120]។

## ការពិភាក្សា

55. ក្រុមមេធាវីការពារក្តីផ្អែកទឡ្ហីករណ៍របស់ខ្លួនលើចំណុចដែលថា កិច្ចស៊ើបសួរដូចមានរៀបរាប់នៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរលេខ D219/647 រំលោភបំពានលើតម្រូវការវិធាន ២៤ នៃវិធានផ្ទៃក្នុង ដោយខ្លួនយល់ឃើញថា "ការសួរ [redacted] អំពីទីតាំងនៃការចោទប្រកាន់ពីការរៀបការដោយបង្ខំ មានតម្លៃស្មើនឹងការសម្ភាសន៍"។

56. ដូចមានកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 ដែលរងការជំទាស់នេះ[121] បន្ទាប់ពីបានកត់សម្គាល់ថា សំណើរបស់ សពអ "សំដៅលើភូមិក្របហុក ក្នុងឃុំបាណន់ ដែលជាទីតាំងស្ថិតនៅក្នុងដែនយុត្តាធិការតុលាការ ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ"[122] និងដោយសារតែ "ភូមិ និងឃុំនោះ មិនស្ថិតនៅក្នុងទិន្នន័យភូមិសាស្ត្រ[123]" គោលបំណងនៃកិច្ចស៊ើបសួរ គឺសម្រាប់អ្នកស៊ើបសួរ បញ្ជាក់ ឬ "*កំណត់ទីតាំងភូមិ*[124]" នោះ។ ការពិនិត្យឡើងវិញលើឯកសារជាប្រភេទ

---

[118] ដូចយោងខាងលើ។ ដែលយោងទៅរក D302/3 សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនិងការចោទប្រកាន់នីមួយៗ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២១, ៣៤។

[119] ការឆ្លើយតប កថាខណ្ឌ ២០។

[120] ដូចខាងលើ។

[121] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 កថាខណ្ឌទីមួយ និងទីពីរ។

[122] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 ឃ្លាដំបូងនៃកថាខណ្ឌទីពីរ យោងទៅសេចក្តីសង្ខេបបន្ថែមអំពីពត៌មានដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០១០(សង្ខេបពត៌មានបន្ថែម) ឯកសារ D65.1.5b។

[123] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 ឃ្លាទីពីរនៃកថាខណ្ឌទីពីរ។

[124] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 ឃ្លាទីបីនៃកថាខណ្ឌទីពីរ។

បានបង្ហាញថា "ពាក្យ "ក្រហុក" អាចជា*កំហុសនៃការប្រកបពាក្យ* នៅក្នុងឯកសារដើមជាភាសាខ្មែរ [D65.1.5a] និងនៅក្នុងឯកសារបកប្រែជាភាសាអង់គ្លេស D65.1.5b ហើយទីតាំងនោះអាចជា "កង្កួត""[125]។

57. **ដើម្បីបំបាត់**មន្ទិលសង្ស័យលើការប្រកបពាក្យ អ្នកស៊ើបអង្កេតបានស្នើអ្នកវិភាគ កសចស ឱ្យទូរស័ព្ទទៅ [redacted] "ដើម្បីសួរព័ត៌មានបន្ថែមអំពីទីតាំងនៃ *ការចោទប្រកាន់* អំពី ការរៀបការដោយបង្ខំ"[126]។ យោងតាមកំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 សាក្សីបាននិយាយតាមទូរស័ព្ទថា "មនុស្ស១៥គូ បានរៀបការនៅក្នុងវត្តមួយនៅជិតទំនប់កង្កួត ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង"[127]។

58. ចៅក្រមដែលបានហត្ថលេខា ជាដំបូង ត្រូវពិចារណាថាតើការហៅទូរស័ព្ទនេះមានតម្លៃស្មើនឹងការសម្ភាសន៍សាក្សីដែរឬទេ ហើយទីពីរ ថាតើការហៅទូរស័ព្ទបែបនេះ ត្រូវបានអនុញ្ញាតតាមច្បាប់ដែរឬទេ។

*ថាតើការហៅទូរស័ព្ទនេះ មានតម្លៃស្មើនឹងការសម្ភាសន៍ដែរឬទេ*

59. ជាការចាប់ផ្តើម ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា វិធានផ្ទៃក្នុងមិនបានកំណត់និយមន័យនៃកិច្ច សម្ភាសន៍ ហើយគ្រាន់តែបង្ហាញលក្ខខណ្ឌមួយចំនួនដែលត្រូវបំពេញប៉ុណ្ណោះ។ ក្នុងន័យនេះ វិធាន ២៤ នៃវិធានផ្ទៃក្នុង មិនអាចជួយដើម្បីកំណត់ថាតើ ការហៅទូរស័ព្ទនេះមានតម្លៃស្មើនឹងការសម្ភាសន៍ដែរឬទេ ក៏ប៉ុន្តែ វិធាននេះអាចជួយកំណត់ភាពត្រឹមត្រូវនៃនីតិវិធី ក្នុងករណីដែលវាមានតម្លៃស្មើនឹងការសម្ភាសន៍។

60. ចៅក្រមដែលបានហត្ថលេខាមិនយល់ថា ការហៅទូរស័ព្ទរយៈពេលខ្លីមួយដើម្បីសួរបញ្ជាក់ពីភាពត្រឹមត្រូវនៃ ការប្រកបពាក្យមួយម៉ាត់នោះ ពិតជាមានតម្លៃស្មើនឹងការសម្ភាសន៍នោះទេ។ ចៅក្រមដែលបានហត្ថលេខា រម្លឹកថា គោលបំណងនៃការហៅទូរស័ព្ទនោះ មិនមែនដើម្បីប្រមូល

---

[125] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 ឃ្លាទីបួននៃកថាខណ្ឌទីពីរ។

[126] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 កថាខណ្ឌទីបី។

[127] ដូចខាងលើ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ភស្តុតាងបន្ថែមទេ។ ការហៅ ទូរស័ព្ទគឺដើម្បីបញ្ជាក់ថាតើ "កំហុសក្នុងការប្រកបពាក្យនៅក្នុងឯកសារដើមជាភាសាខ្មែរ និង ឯកសារបកប្រែជាភាសាអង់គ្លេស" ទាក់ទងទៅនឹងឈ្មោះនៃទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ បានកើតមានឡើងឬយ៉ាងណា។ ចៅក្រមដែលបានហត្ថលេខាកត់សម្គាល់ថា ការផ្ទៀងផ្ទាត់នេះកាន់តែមានភាពចាំបាច់ ដោយសារថា ព័ត៌មានអំពីការចោទប្រកាន់បន្ថែមទៀតដែលត្រូវបានផ្តល់ដោយ សាក្សីដែលបានប្រកបពាក្យទីតាំងនៃការរៀបការដោយបង្ខំដែលមានការចោទប្រកាន់ ដោយសរសេរថា "ក្របាត"[128] ហើយមិនមែន "ក្របុក"[129] ទេ។

61. ទោះបីជាការហៅទូរស័ព្ទនោះមានតម្លៃស្មើនឹងការសម្ភាសន៍ក៏ដោយ ក៏ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា អ្នកស៊ើបអង្កេតនៅមានជម្រើសដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួនតាមរយៈការសម្ភាសន៍សាក្សី។ ទោះជាយ៉ាងនេះក៏ដោយនៅតែមានសំណួរដដែល ដែលថា តើការហៅទូរស័ព្ទបែបនេះត្រូវបានអនុញ្ញាតតាមច្បាប់ដែរឬទេ។

*តើការហៅទូរស័ព្ទបែបនេះត្រូវបានអនុញ្ញាតតាមច្បាប់ដែរឬទេ*

62. ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា ទោះជាវិធាន ២៤ នៃវិធានផ្ទៃក្នុង កំណត់ក្របខណ្ឌច្បាប់ច្បាស់ លាស់សម្រាប់ការសម្ភាសន៍សាក្សី វិធាននេះមិនបានហាមឃាត់ឲ្យជាក់លាក់អំពីមធ្យោបាយផ្សេងៗទៀតសម្រាប់ទាក់ទងសាក្សី ដើម្បីបញ្ជាក់ព័ត៌មានណាមួយដែលពួកគេអាចមានទេ។ ចៅក្រមដែលបានហត្ថលេខារម្លឹកថា បញ្ហាសុពលភាពនៃការទាក់ទងរវាងអ្នកស៊ើបអង្កេត និងសាក្សី ដើម្បី រៀបចំការសម្ភាសន៍សាក្សីនោះ ជាឧទាហរណ៍ ត្រូវបានលើកឡើងរួចមកហើយនៅក្នុងករណីមួយផ្សេងទៀត[130]។ ចៅក្រមដែលបានហត្ថលេខាពុំឃើញមានបញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុង ដែលត្រូវបានចែងជាពិសេសសម្រាប់គ្រប់គ្រងការទាក់ទងប្រភេទនេះ។ ដូច្នេះ ការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលថា ការហៅទូរស័ព្ទនោះមានតម្លៃនឹងការសម្ភាសន៍លើអង្គសេចក្តី និងជាផ្លូវការនោះ គឺជាការស្មានសុទ្ធសាធ។

---

[128] ព័ត៌មានបន្ថែមពីអ្នកស្នើសុំដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D65.1.5a កថាខណ្ឌទីពីរ ប្រើពាក្យ "ក្របាត"។

[129] សង្ខេបព័ត៌មានបន្ថែម ឯកសារ D65.1.5b ប្រើពាក្យ "ក្របុក"។

[130] សេចក្តីសម្រេចលើសំណើទាំងប្រាំបួន កថាខណ្ឌ១២។

63. ជាការចាប់ផ្តើម ចៅក្រមដែលបានហត្ថលេខារម្លឹកថា វិធាន ៥៥(៥) ចែងថា “ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរ ដែលអាចនាំទៅរកការបង្ហាញការពិត”។ មាត្រា ១៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ចៅក្រមស៊ើបសួរអាចសុំឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពណាមួយនៃនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស។ កាន់តែជាក់ច្បាស់ជាងនេះទៀត មាត្រា ១៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា “មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន”។ វិធាន ៤២(៣)(ក) នៃវិធានផ្ទៃក្នុង ក៏មានប្រើពាក្យពេចន៍ស្រដៀងគ្នានេះដែរ។

64. នៅក្នុងករណីនេះ ចៅក្រមដែលបានហត្ថលេខាកត់សម្គាល់ឃើញថា កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/ 647 ត្រូវបានធ្វើឡើង “*ដោយយោងលើដីកាចាត់ឱ្យស៊ើបសួរជំនួស D219*”[131]។ ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ណែនាំអ្នកស៊ើបអង្កេតឱ្យ “រៀបចំ *ឬបំពេញកំណត់ត្រានៃការកំណត់អត្តសញ្ញាណដែលមានស្រាប់ ដោយបញ្ជាក់ទីតាំងពិតប្រាកដ និងពណ៌នាលក្ខណៈចរិកនៃទីតាំងនីមួយៗ* ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ និងទីតាំងទាំងអស់ដែលភ្ជាប់ជាមួយ ឬទាក់ទងនឹងទីតាំង[ទាំងនោះ]”[132]។

65. ចៅក្រមដែលបានហត្ថលេខាក៏កត់សម្គាល់ដែរថា កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 មានចំណងជើងថា “កំណត់ហេតុនៃកិច្ចស៊ើបសួរ” ហើយមិនមែនជា “កំណត់ហេតុនៃកិច្ចសម្ភាសន៍” ទេ។ ចៅក្រមដែលបានហត្ថលេខាក្រោយពីបានពិនិត្យឡើងវិញនូវកំណត់ហេតុដែលរងការជំទាស់នេះ យល់ឃើញថា ចំណងជើងឆ្លុះបញ្ចាំងពីលក្ខណៈនៃសកម្មភាពដែលត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ហេតុនោះ ដែលមិនអាចចាត់ទុកថាជាកិច្ចសម្ភាសន៍នោះទេ។ ដូច្នេះ វិធាន ២៤ នៃវិធានផ្ទៃក្នុង មិនគ្រប់គ្រងនិយ័តភាពនៃកំណត់ហេតុនេះទេ។

---

[131] កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 កថាខណ្ឌទីមួយ។

[132] ដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ERN01023880 ផ្នែក “ក”។

01522701



66. ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា សចស ក៏មានឆន្ទានុសិទ្ធិពិនិត្យមើលកិច្ចសម្ភាសន៍សាក្សី ឬតាមរយៈ "កិច្ចស៊ើបសួរណាមួយដែលនាំទៅរកការបង្ហាញការពិត" ដើម្បីធ្វើការបញ្ជាក់ពីភាពមិនច្បាស់លាស់ណាមួយពីឈ្មោះត្រឹមត្រូវនៃទីតាំង "ក្របុក" ឬ "ក្របាត"[133]។

67. ចៅក្រមដែលបានហត្ថលេខាចាត់ទុកថា ភាពមិនច្បាស់លាស់នៃឈ្មោះទីតាំងនានា ដោយសារកំហុសនៃការបកប្រែ តែងតែជាលទ្ធភាពមួយ ហើយជួនកាល អាចនាំឱ្យមានការភ័ន្តច្រឡំ ប្រសិនបើមិនត្រូវបានបញ្ជាក់ឱ្យច្បាស់។ ការដែលថា ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុងករណីនេះ គឺជាចំណុចវិជ្ជមានទៅវិញទេ។

68. ក្នុងការធ្វើកំណត់ហេតុនៃកិច្ចស៊ើបសួរ ដោយអនុលោមតាមការណែនាំនៃដីកាចាត់ឱ្យស៊ើបសួរជំនួស និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ សចស អ្នកស៊ើបអង្កេតបានពណ៌នាត្រឹមត្រូវនូវការស្រាវជ្រាវ និងការរកឃើញរបស់ខ្លួន ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃការប្រកបពាក្យនៃឈ្មោះទីតាំងដែលបានលើកឡើងរួចមកហើយនៅក្នុងការចោទប្រកាន់របស់ [redacted][134]។ កំណត់ហេតុដែលរងការជំទាស់ មិននាំឱ្យមានអ្វីថ្មីទេ ប៉ុន្តែគ្រាន់តែជាការកែតម្រូវសាមញ្ញមួយលើការប្រកបឈ្មោះនៃទីតាំងដែលបានលើកឡើងរួចមកហើយ។

69. ជាចុងក្រោយ ចៅក្រមដែលបានហត្ថលេខាកត់សម្គាល់ថា ចាប់តាំងពីកំណត់ហេតុនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ហើយភាគីទាំងអស់អាចពិនិត្យមើលបាន ដំណើរការនីតិវិធីនៅតែមានភាពយុត្តិធម៌ និងរក្សានូវតុល្យភាពនៃសិទ្ធិរបស់ភាគីនានា។ ចំណុចនេះត្រូវបានបង្ហាញតាមរយៈលទ្ធភាពដែលក្រុមមេធាវីការពារក្តីមាន ក្នុងការដាក់សំណើសុំមោឃភាពដោយផ្អែកលើមូលដ្ឋានជាក់ច្បាស់មួយនេះ ហើយដោយហេតុថា ក្រុមមេធាវីការពារក្តីមានឱកាសស្នើសុំធ្វើសម្ភាសន៍ [redacted] ផងដែរ[135]។

70. ដូច្នេះ ចៅក្រមដែលបានហត្ថលេខាយល់ឃើញថាពុំមានវិការៈផ្នែកនីតិវិធីនោះទេ។

---

[133] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

[134] ឯកសារ D65.1.5a និងឯកសារ D65.1.5b។

[135] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

### v) ថាតើសិទ្ធិរបស់ជនត្រូវចោទត្រូវបានរងព្យសនកម្មដែរឬទេ

### សារណា

71. សហមេធាវីលើកឡើងថា វិការៈផ្នែកនីតិវិធីដែលត្រូវបានចោទប្រកាន់នេះ "បានបង្កជាព្យសនកម្មជាបុគ្គល និងជារួម ដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់[redacted] ដូចជា សិទ្ធិទទួលព័ត៌មានពីសំណុំរឿងប្រឆាំងរូបគាត់ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារក្តី"[136]។ សហមេធាវីយល់ឃើញថា ការការពារសិទ្ធិទាំងអស់នេះ "អាស្រ័យទៅលើ សពអ ដែលកំណត់ពីកម្រិតនៃការចោទប្រកាន់"[137] និងដោយ "សចស ដែលកំណត់ពីវិសាលភាពនៃកិច្ចស៊ើបសួរ នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស"[138] ដែលចំណុចទាំងនេះ បន្ទាប់មក "អនុញ្ញាតឱ្យមេធាវីការពារក្តី ត្រៀមរៀបចំសំណុំរឿងរបស់ពួកគេ និងធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរបានសមស្រប"[139]។ ការខកខានកំណត់អត្តសញ្ញាណទំនប់កង្កួត នាំឱ្យជនត្រូវចោទបាត់បង់ឱកាសនេះ ដូច្នេះ សហមេធាវីការពារក្តីស្នើសុំមោឃភាព "កិច្ចស៊ើបសួរទាំងអស់ពាក់ព័ន្ធនឹងទំនប់កង្កួត ដែលត្រូវបានធ្វើឡើងនៅអំឡុងពេលរវាងការដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី [...] និងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន"[140]។

72. សពអ ឆ្លើយតបថា "[redacted] ពិតជាខកខានមិនបានពន្យល់ ឬផ្តល់ភស្តុតាងពីរបៀបដែលថាតើវិការៈផ្នែកនីតិវិធីដូចដែលបានចោទប្រកាន់នោះ វាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់"[141]។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដោយសារគាត់បានដឹងពីអង្គហេតុពាក់ព័ន្ធនឹងទំនប់កង្កួត ចាប់តាំងពីពេលដែលគាត់ត្រូវបានចោទប្រកាន់ និងទទួលសិទ្ធិចូលពិនិត្យមើលសំណុំរឿងផងដែរ ដូច្នេះ ការអះអាងរបស់ [redacted] ដែលថា គាត់ត្រូវបានគេដកឱកាសមិនឱ្យធ្វើសំណើសុំបំពេញ

---

[136] សំណើ កថាខណ្ឌ ៦៤។

[137] សំណើ កថាខណ្ឌ ៦៥។

[138] សំណើ កថាខណ្ឌ ៦៦។

[139] ដូចខាងលើ។

[140] សំណើ កថាខណ្ឌ ៦៧។

[141] ចម្លើយតប កថាខណ្ឌ ២៦។

កិច្ចស៊ើបសួរឱ្យបានសមស្រប គឺគ្មានមូលដ្ឋានទេ[142]។ ទីពីរ សពអ ស្នើថា [redacted] គ្រាន់តែធ្វើ "ការអះអាងបែបទូទៅ"[143] និងមិនបានបំពេញ "បន្ទុកនៃការបង្ហាញនូវការបាត់បង់សិទ្ធិឡើយ"[144]។

73. ក្នុងការឆ្លើយតបទៅនឹងចំណុចទីមួយនៃចម្លើយតបរបស់ សពអ សហមេធាវីស្នើឡើងថា លទ្ធភាពរបស់ [redacted] ក្នុងការរៀបចំសំណុំរឿងរបស់គាត់ "មិនកំណត់ត្រឹមសមត្ថភាពក្នុងការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរឱ្យសមស្រប"[145]។ លើសពីនេះទៀត សហមេធាវីធ្វើការបញ្ជាក់ជាថ្មីអំពីទឡ្ហីករណ៍របស់ខ្លួនទាក់ទងនឹងឥទ្ធិពលនៃដីកាចាត់ឱ្យស៊ើបសួរជំនួស និងសេចក្តីថ្លែង ការណ៍របស់សចសអ ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការចោទប្រកាន់របស់ [redacted][146]។

## ការពិភាក្សា

74. ចៅក្រមដែលបានហត្ថលេខារម្លឹកថា ការពិនិត្យមើលសំណើសុំមោឃភាព តម្រូវឱ្យមាន (១) ការពិចារណា ដំបូង លើវិការៈផ្នែកនីតិវិធី និង (២) ជាបន្ទាប់ នៅពេលដែលមានវិការៈនោះ អត្ថិភាពនៃការរងព្យសនកម្មរបស់អ្នកដាក់សំណើ[147]។ ដោយហេតុថា ពុំមានវិការៈផ្នែកនីតិវិធីណាមួយត្រូវបានរកឃើញ ចៅក្រមដែលបានហត្ថលេខានឹងមិនពិចារណាលើការអះអាងលើការរំលោភសិទ្ធិរបស់ជនត្រូវចោទទេ។

75. ដូច្នេះ ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា ពុំចាំបាច់ត្រូវមានការអន្តរាគមន៍របស់ខ្លួនឡើយ។

---

[142] ដូចខាងលើ។

[143] ចម្លើយតប កថាខណ្ឌ ២៧។

[144] សូមមើលចម្លើយតប កថាខណ្ឌ ៧។

[145] ការឆ្លើយតប កថាខណ្ឌ ១៨ យោងលើសំណើ កថាខណ្ឌ ៦៦។

[146] ការឆ្លើយតប កថាខណ្ឌ ១៩-២០។

[147] សេចក្តីសម្រេចលើសំណើចំនួនពីររបស់ [redacted] កថាខណ្ឌ ២៥ *សូមមើលផងដែរ* សេចក្តីសម្រេចលើ នួន ជា កថាខណ្ឌ ៣៤។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

01522704



## ខ. សំណើសុំមោឃភាពសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ដោយមានការកែតម្រូវ និងកិច្ចស៊ើបសួរដែលពាក់ព័ន្ធ

### សារណា

76. សហមេធាវីយល់ឃើញថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ដោយមានការកែតម្រូវ គឺដើម្បី "*កែតម្រូវ*" សំណើសុំបញ្ចូលការចោទប្រកាន់ថ្មី ប្រឆាំងលោក [redacted] គឺ ការរៀបការដោយបង្ខំទាំង១៥គូនៅ ទំនប់កង្ហត"[148]។ សហមេធាវីស្នើថា នេះគឺជាវិការៈផ្នែកនីតិវិធី ដោយហេតុថា ដំបូង "*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* បញ្ជាទៅ សចអ ឱ្យដាក់ការកែតម្រូវ [...] សចសអ បានរំលោភបុព្វសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការកំណត់វិសាលភាព"[149] និងទីពីរ "ដោយដាក់ការកែតម្រូវ" សចអ មិនបានគោរពតាម នីតិវិធីសម្រាប់*ការពង្រីក* វិសាលភាពនៃកិច្ចស៊ើបសួរ"[150] តាមរយៈសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬការបំភ្លឺណាមួយ។ ដូច្នេះ និងដោយសារតែមានការប៉ះពាល់ សហមេធាវីស្នើសុំមោឃភាពសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួនដែលមានការកែតម្រូវ ព្រមទាំងកិច្ចស៊ើបសួរទាំងអស់ ដែលធ្វើឡើងបន្ទាប់ពីដីកានេះត្រូវបានដាក់ ដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធ[151]។

77. សចអ ឆ្លើយតបថា គាត់បានដាក់ការកែតម្រូវ "*ដើម្បីឆ្លុះបញ្ចាំងពី[ការ]បំភ្លឺ*"[152] ពាក់ព័ន្ធនឹងព័ត៌មានបន្ថែមនៃការចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] និង "*ជាការឆ្លើយតបទៅនឹងសេចក្តីបំភ្លឺបន្តបន្ទាប់របស់ កសចស*"[153]។ ទាក់ទងនឹងកិច្ចស៊ើបសួរដែលត្រូវបានធ្វើឡើងក្រោយថ្ងៃទី១៦ ខែមេសា "ដោយមានជាកំណត់ហេតុនៃកិច្ចសម្ភាសន៍ចំនួនពីរ"[154] សចអ ស្នើឡើងថា កិច្ចស៊ើបសួរនេះត្រូវបានធ្វើឡើង "អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស D219 ដែលមាន

---

[148] សំណើ កថាខណ្ឌ ៦៨។

[149] សំណើ កថាខណ្ឌ ៦៩។

[150] សំណើ កថាខណ្ឌ ៧០។

[151] សំណើ កថាខណ្ឌ ៧១។

[152] ចម្លើយតប កថាខណ្ឌ ២៥។

[153] ដូចខាងលើ។

[154] ចម្លើយតប កថាខណ្ឌ ២៧។

សុពលភាព”[155] ហើយថា “ពុំមានសញ្ញាបង្ហាញថា គ្មានកិច្ចស៊ើបសួរណាមួយនៃ [កិច្ចស៊ើបសួរទាំងនេះ] ត្រូវបានដឹកនាំធ្វើ ផ្អែកលើលទ្ធផលនៃការកែតម្រូវនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីររបស់ សចពអ ឡើយ”[156]។

78. ក្នុងការឆ្លើយតប សហមេធាវីលើកឡើងជាថ្មីថា ការកែតម្រូវ “នោះឯង គឺជាវិការៈផ្នែកនីតិវិធី”[157] ហើយថា សចពអ មានកំហុសក្នុងការអះអាងថា ដីកាចាត់ឱ្យស៊ើបសួរជំនួស D118 និង D219 គ្របដណ្តប់ការស៊ើបអង្កេតនៅទំនប់កង្ហត[158]។

## ការពិភាក្សា

79. សហមេធាវីអះអាងថា ការកែតម្រូវនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបួន មិនត្រឹមត្រូវផ្នែកនីតិវិធីទេ ដោយសារ ១) ដីកានោះមានបំណង*ដាក់បញ្ចូលការចោទប្រកាន់ថ្មីមួយ* ប្រឆាំងនឹងអ្នកដាក់សំណើ គឺការរៀបការដោយបង្ខំចំនួន១៥គូនៅទំនប់កង្ហត និង ២) ក្នុងការចេញដីកានេះ *សចពអ មិនបានគោរពតាមនីតិវិធីនៃការពង្រីកវិសាលភាព* នៃការស៊ើបអង្កេតទេ។

80. ជាដំបូង ចៅក្រមដែលបានហត្ថលេខាររំឭកថា អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ បានស្នើឱ្យ សចសអ ធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្ហត[159]។

81. លើសពីនេះទៀត បន្ទាប់ពីបានពិនិត្យមើលខ្លឹមសារនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ចៅក្រមដែលបានហត្ថលេខាកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋាននេះគឺមានពីរផ្នែក ដោយផ្នែកទីមួយមានចំណងជើងថា “ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ”[160]

[155] ដូចខាងលើ។

[156] ដូចខាងលើ។

[157] ការឆ្លើយតប កថាខណ្ឌ ១៦។

[158] ការឆ្លើយតប កថាខណ្ឌ ១២។

[159] សូមមើលដូចខាងលើ កថាខណ្ឌ ៣១។

[160] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន កថាខណ្ឌ ៤-៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

និងផ្នែកទីពីរ មានចំណងជើងថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"[161]។ ក្នុងផ្នែកទីមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន សពអ ពិតជាបានបំភ្លឺថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ មានបំណងស្នើ សចស ឱ្យធ្វើការស៊ើបអង្កេតលើការរៀបការដោយបង្ខំនៅទីតាំងទាំងនោះ[162] រួមបញ្ចូលទាំង ទំនប់កង្គត[163] និង "ការយោងទៅ "ឧក្រិដ្ឋកម្មដទៃទៀត" នៅក្នុងកថាខណ្ឌទី ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម [លើកទីពីរ] *មិនមាន បំណងពង្រីក* ការស៊ើបអង្កេតហួសពីវិសាលភាពដែលត្រូវបានកំណត់ពីមុននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបីរបស់សហព្រះរាជអាជ្ញា"[164]។ ផ្នែកទីមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន មិនបានស្នើឱ្យ កសចស ចាប់ផ្ដើមការស៊ើបអង្កេតផ្លូវតុលាការណាមួយឡើយ ដែលការស្នើនេះ ត្រូវបានធ្វើឡើងច្បាស់លាស់នៅក្នុងផ្នែកទីពីរ ដែលមានចំណងជើងថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ពាក់ព័ន្ធនឹងការចោទប្រកាន់ពីការរៀបការដោយបង្ខំនៅស្រុកសំឡូត[165]។ មានការបែងចែករវាងផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ដែលបំភ្លឺអំពីវិសាលភាពនៃការស៊ើបអង្កេត ដោយធ្វើការ ពន្យល់អំពីអង្គហេតុដែលត្រូវបានយល់ថាស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងផ្នែកទីពីរ ដែលរួមទាំងអង្គហេតុថ្មីៗ។ សុពលភាពនៃផ្នែកទីពីរនៃដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរបន្ថែមលើកទីបួននេះ មិនត្រូវបានតវ៉ាដោយក្រុមមេធាវីការពារក្ដីនៅក្នុងសំណើរបស់ខ្លួនទេ។ តាមការពិត ក្រុមមេធាវីការពារក្ដីក៏មិនបានតវ៉ាផ្នែកទីមួយនៃដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន (D272/1) ដែរ។ មានតែសុពលភាពនៃ "ការកែតម្រូវ" បន្ទាប់ ដែលត្រូវបានធ្វើនៅក្នុងផ្នែកទីមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[161] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន កថាខណ្ឌ ១០-១៥។

[162] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន កថាខណ្ឌ ៦។

[163] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ឯកសារ D272/1 កថាខណ្ឌ ៦(ខ) យោងទៅ "ភូមិក្រហុក"។ សូមមើលផងដែរ ឯកសារ D212/1/Corr-1 កថាខណ្ឌ ៦(ខ) យោងទៅ "ទំនប់កង្គត"។

[164] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ឯកសារ D272/1 កថាខណ្ឌ ៧

[165] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ឯកសារ D272/1 កថាខណ្ឌ ១២៖ "សពអស្នើឱ្យមានការស៊ើបអង្កេតផ្លូវតុលាការលើការរៀបការដោយបង្ខំនៅស្រុកសំឡូត ក្នុងឆ្នាំ១៩៧៨"។

បន្ថែមលើកទីបួន (D272 /1-Corr-1) ដែលត្រូវបានតវ៉ា[166]។ នៅក្នុងបរិបទនេះ ចៅក្រមដែលបានហត្ថលេខា ដំបូង កត់សម្គាល់ពីការកែតម្រូវលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ដែលបានដាក់ "ជាការឆ្លើយ តបទៅនឹងការបំភ្លឺបន្តបន្ទាប់របស់ កសចស"[167] និងទីពីរ រម្លឹកថា ចៅក្រមដែលបានហត្ថលេខាបានយល់ឃើញថា "កំណត់ហេតុដែលរងការជំទាស់ [រួមទាំងកំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647] *មិននាំឱ្យមានអ្វីថ្មីទេ ប៉ុន្តែគ្រាន់តែជាការកែតម្រូវសាមញ្ញមួយលើការប្រកបឈ្មោះនៃទីតាំង ដែលបានលើកឡើងរួចមកហើយ* [នៅក្នុងសេចក្តីថ្លែងការណ៍របស់ [redacted]]"[168]។

82. ចៅក្រមដែលបានហត្ថលេខាពិចារណាបន្ថែមទៀតថា ទោះជាតម្រូវការទម្រង់បែបបទនៃវិធាន ៥៣(១) នៃ វិធានផ្ទៃក្នុង ត្រូវអនុវត្តលើផ្នែកទីពីរនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន[169] ការដែលថា ផ្នែកទីមួយត្រូវបានដាក់សម្រាប់គោលបំណងបំភ្លឺប៉ុណ្ណោះ មិនមែនជាមូលដ្ឋានសម្រាប់ជំទាស់អំពីអសុពលភាពផ្នែកនីតិវិធីនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួនឡើយ។ យ៉ាងណាក៏ដោយ ដោយធ្វើការបញ្ជាក់ច្បាស់លាស់អំពីអង្គហេតុដែលបានដាក់បញ្ចូលរួចហើយ ផ្នែកទីមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន រួមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួនដែលមានការកែតម្រូវ បំពេញលក្ខខណ្ឌជាផ្លូវការនៃវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង។

83. ចៅក្រមដែលបានហត្ថលេខាក៏យល់ឃើញដែរថា ការបែងចែកកិច្ចការសម្រាប់សហព្រះរាជអាជ្ញា និងសហ ចៅក្រមស៊ើបអង្កេត គឺជាលក្ខណៈជាមូលដ្ឋាននៃប្រព័ន្ធសួរដេញដោលដោយចៅក្រម។

---

[166] សំណើ ទំព័រ ១៨ (ឈ)៖ "ការកែតម្រូវនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន មានវិការៈផ្នែកនីតិវិធី" និងកថាខណ្ឌ ៦៨-៧១។

[167] ចម្លើយតប កថាខណ្ឌ ២៤ និងជើងទំព័រ ៤៦ *យោងទៅ* កំណត់ហេតុនៃកិច្ចស៊ើបសួរ D219/647 (បន្ថែមការបញ្ជាក់ន័យ)។

[168] សូមមើលខាងលើ កថាខណ្ឌ៦៨។

[169] សូមមើលសំណុំរឿង ០០២ (អបជ៤៧ និង អបជ៤៨) សេចក្តីសម្រេចរួមលើសំណើទាំងពីររបស់សហព្រះរាជអាជ្ញា ស្នើសុំកិច្ចស៊ើបសួរ ទាក់ទងនឹងខ្មែរក្រោម និងការសម្រាប់ទ្រង់ទ្រាយធំនៅស្រុកបាកាន (ខេត្តពោធិ៍សាត់) និង សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំការស៊ើបអង្កេតបន្ថែម ទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ D250/3/3 កថាខណ្ឌ ៦។

ដូចមាន ចែងក្នុងវិធាន ៥៥(២) "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតតែអង្គហេតុណាដែល មានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (របស់សហព្រះរាជអាជ្ញា)"។ កិច្ចការសម្រាប់សហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា ត្រូវបានកំណត់យ៉ាងច្បាស់លាស់។ ការដែលសហព្រះរាជអាជ្ញាអន្តរជាតិបំភ្លឺអំពីវិសាលភាពនៃការស៊ើបអង្កេត ជួយដល់សហចៅក្រមស៊ើបអង្កេតឱ្យគោរពវិធាននេះ នៅពេលធ្វើការស៊ើបអង្កេតអង្គហេតុនានាដែលស្ថិតនៅក្រោមវិសាលភាពនោះ។

84. ដោយសារសំណើសុំមោឃភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួនដែលមានការកែតម្រូវ មិនមានមូលដ្ឋានត្រឹមត្រូវ និយ័តភាពផ្នែកនីតិវិធីនៃកិច្ចស៊ើបសួរដែលពាក់ព័ន្ធ ក៏មិនមែនជាបញ្ហាដែរ។

85. ដូច្នេះ មូលដ្ឋានសម្រាប់មោឃភាពនេះត្រូវបានបដិសេធ។

## គ. សំណើសុំមោឃភាពដីកាចោទប្រកាន់[redacted] ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅទំនប់កង្កួត

### សារណា

86. សហមេធាវីកត់សម្គាល់បញ្ញត្តិនៃវិធាន ៧៦(៥) ហើយស្នើឡើងថា សេចក្តីសម្រេចចោទប្រកាន់ "អាចស្ថិតក្នុងវិសាលភាព [នៃ] កិច្ច ឬដីកា មួយ ដែលអាចធ្វើមោឃភាព"[170]។ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពបទចោទ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្កួត និងច្រានចោលផ្នែកពាក់ព័ន្ធនៃកំណត់ហេតុការបង្ហាញខ្លួនជាលើកដំបូង ដោយមូលហេតុថា ផ្នែកទាំងនោះត្រូវបានគាំទ្រដោយកិច្ចស៊ើបសួរនៅទំនប់កង្កួតដែលត្រូវបានចោទប្រកាន់ថាមានវិការៈ[171]។

---

[170] សំណើ កថាខណ្ឌ ៧២។

[171] សំណើ កថាខណ្ឌ ៧៣។

87. ក្នុងចម្លើយតប សពអ ស្នើឡើង ជាទូទៅ ថា សហមេធាវី “ខកខានក្នុងការបង្ហាញពីកំហុសនីតិវិធីទាក់ទងនឹងកិច្ចការស៊ើបសួរនៅ [ទំនប់កង្កួត]”[172] ហើយថា “ប្រសិនបើ [អង្គបុរេជំនុំជម្រះ] ផ្តល់ការអនុញ្ញាតឱ្យមានការធ្វើមោឃភាពឯកសារចោទប្រកាន់របស់ សចស ដោយសារវាពាក់ព័ន្ធនឹង [ទំនប់កង្ហាត] នោះ សចស នឹងត្រូវមានសេរីភាពក្នុងការប្រមូលភស្តុតាងដូចគ្នាបេះបិទជាថ្មីម្តងទៀត [ដែល] នាំឱ្យមានការចំណាយពេល និងធនធានឥតប្រយោជន៍”[173]។

88. នៅក្នុងការឆ្លើយតប សហមេធាវី ជាទូទៅ លើកឡើងជាថ្មីថា ការស៊ើបអង្កេតនៅទំនប់កង្កួត មានវិការៈផ្នែកនីតិវិធី។

## ការពិភាក្សា

89. ចៅក្រមដែលបានហត្ថលេខាកាលពីលើកមុន បានទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដោយឈរលើមូលដ្ឋានថា វាមានតម្លៃស្មើនឹង “ការជំទាស់យុត្តាធិការ” ដោយអនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលត្រូវការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ នៅក្នុងករណីលើកលែង[174]។

90. ចៅក្រមដែលបានហត្ថលេខាយល់ស្របថា សេចក្តីសម្រេចដាក់ឱ្យស្ថិតក្រោមការពិនិត្យ អាចស្ថិតនៅក្រោមវិសាលភាព [នៃ] កិច្ច ឬ ដីកា ដែលអាចធ្វើមោឃភាព ជាជាង អាចប្តឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង។

---

[172] ចម្លើយតប កថាខណ្ឌ ១។

[173] ចម្លើយតប កថាខណ្ឌ ២៩។

[174] សំណុំរឿង ០០៤ ០៧-០៩-២០០៩ អវតក/កសចស (អបជ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់ [redacted] ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ២៣។ សូមមើលផងដែរ សំណុំរឿង ០០៣ (អបជ២១) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ [redacted] ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9 កថាខណ្ឌ ២៩-៣០។

91. ចៅក្រមដែលបានហត្ថលេខាកត់សម្គាល់ថា [redacted] តាមពិត ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ បន្ទាប់ពីការបង្ហាញខ្លួនជាលើកដំបូង ចំពោះឧក្រិដ្ឋកម្មជាច្រើនផ្សេងគ្នា ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅទំនប់កង្កួត[175]។

92. លើសពីនេះទៀត ចៅក្រមដែលបានហត្ថលេខាបានពិចារណាលើទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី និង ធ្វើការបញ្ជាក់ថាតើ ការស៊ើបអង្កេតនៅទំនប់កង្កួត មិនត្រឹមត្រូវតាមនីតិវិធីដែរឬទេ។ ចៅក្រមដែលបានហត្ថលេខាបានធ្វើការសន្និដ្ឋានថា វិការៈផ្នែកនីតិវិធីមិនបានកើតមានឡើយ។ ជាពិសេស កសចស បានទទួលពិនិត្យត្រឹមត្រូវលើឧក្រិដ្ឋកម្មដែលខ្លួនបានចោទប្រកាន់លើ [redacted]។

93. ដូច្នេះហើយ ចៅក្រមដែលបានហត្ថលេខាយល់ឃើញថា សេចក្តីសម្រេចដាក់ [redacted] ឱ្យស្ថិតក្រោមការ ពិនិត្យពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទំនប់កង្កួត មិនត្រូវបានប៉ះពាល់ដោយកំហុសនីតិវិធីណាមួយ ដូចដែលក្រុមមេធាវីការពារក្តីបានអះអាងឡើយ។

94. ដូច្នេះ ផ្នែកនៃសំណើនេះត្រូវបានបដិសេធ។

95. ជាការសន្និដ្ឋាន ចៅក្រមដែលបានហត្ថលេខាបដិសេធសំណើទាំងស្រុង។

**រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧**

**Olivier BEAUVALLET** **Kang Jin BAIK**

[175] កំណត់ហេតុបង្ហាញខ្លួនលើកដំបូង ឯកសារ D281 ទំព័រ៣, ៤,៨ និង ១៤។